## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ក្រសួងអប់រំ យុវជន និងកីឡា

## កម្មវិធីសិក្សាលម្អិតសម្រាប់

## ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម
(បរិញ្ញាបត្រ+២)

# មុខវិជ្ជារួមនៃឯកទេស

### វិទ្យាស្ថានជាតិអប់រំ

មេសា ២០២២

# មុខកថា

និន្នាការអប់រំសកល និងតំបន់ នាសតវត្សទី២១ មានការប្រែប្រួលដោយសារការវិវត្តនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក៏ដូចជាតម្រូវការជាក់ស្តែងរបស់សង្គមជាតិ។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ទី៤ ផ្តោតសំខាន់លើការអប់រំប្រកបដោយគុណភាព ដែលប្រទេសនីមួយៗត្រូវតែសម្រេចឱ្យបានត្រឹមឆ្នាំ២០៣០។

រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលកំណត់ **ការអភិវឌ្ឍធនធានមនុស្ស** ជាអាទិភាពទីមួយ។ គោលដៅចម្បងរបស់រាជរដ្ឋាភិបាលគឺការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព តាមរយៈការបណ្តុះបណ្តាលមនុស្ស ឱ្យក្លាយទៅជាពលរដ្ឋពេញលេញដែលមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ។

ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ស៊ីជម្រៅលើគ្រប់អនុវិស័យ ក្នុងនោះការអភិវឌ្ឍកម្មវិធីសិក្សា គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពអប់រំនៅកម្ពុជា។ ឈរលើស្មារតីនេះ វិទ្យាស្ថានជាតិអប់រំ បានបង្កើតគណៈកម្មការកែលម្អកម្មវិធីបណ្តុះបណ្តាលនៅគ្រប់មុខវិជ្ជាសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) ដោយមានការសហការជាមួយភាគីពាក់ព័ន្ធដូចជាអង្គការខេប(KAPE) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

កម្មវិធីបណ្តុះបណ្តាលលម្អិតសម្រាប់ការបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តម(បរិញ្ញាបត្រ+២)នេះ ត្រូវបានរៀបចំជា៥ផ្នែក គឺមុខវិជ្ជារួមនៃឯកទេស មុខវិជ្ជាស្នូលនៃឯកទេស និងមុខវិជ្ជាជម្រើស។ នៅក្នុងឯកសារនេះ មានវត្ថុបំណងរួម ខ្លឹមសារមេរៀន លទ្ធផលសិក្សារំពឹងទុក និងចំនួនក្រេឌីតសិក្សាតាមលំដាប់លំដោយ។ គរុនិស្សិតនឹងទទួលបានការបណ្តុះបណ្តាលប្រកបដោយគុណភាព ដើម្បីធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ការរៀន និងបង្រៀននៅតាមគ្រឹះស្ថានសិក្សារបស់ពួកគាត់នាពេលអនាគត។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា ឯកសារនេះនឹងបានជាប្រយោជន៍ដល់អ្នកអនុវត្ត ជាពិសេសគរុនិស្សិតដែលទទួលបានការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ដើម្បីយកវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ទៅអនុវត្តក្នុងការបង្រៀនប្រកបដោយគុណភាព ប្រសិទ្ធភាព និងជំរុញឱ្យការអប់រំនៅកម្ពុជាមានភាពជឿនលឿន ដូចប្រទេសនានាក្នុងតំបន់ និងសកលលោក។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ក្នុងការអភិវឌ្ឍប្រទេសជាតិ ធនធានមនុស្សជាកម្លាំងយ៉ាងសំខាន់ សម្រាប់ធ្វើឱ្យការអភិវឌ្ឍសង្គមជាតិទទួលបានជោគជ័យ។ គោលដៅចម្បងរបស់ផែនការអភិវឌ្ឍសង្គម សេដ្ឋកិច្ច គឺការរៀបចំប្រជាជនយើងឱ្យក្លាយទៅជាពលរដ្ឋពេញលេញ គឺជាពលរដ្ឋល្អ ពលរដ្ឋថ្លៃថ្នូរ និងពលករជំនាញ។ ការអប់រំជាយុទ្ធសាស្ត្រយ៉ាងសំខាន់ដើម្បីឈានទៅសម្រេចគោលដៅនេះឱ្យបានជោគជ័យ។

ដូចនេះ កំណែលម្អវិស័យអប់រំ ជាការធានានូវការលើកកម្ពស់គុណភាពអប់រំ ដែលជានិន្នាការរួមរបស់បណ្ដាប្រទេសក្នុងពិភពលោក។ ឯការអភិវឌ្ឍកម្មវិធីសិក្សាលម្អិត គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពអប់រំ។ ឈរលើស្មារតីនេះ វិទ្យាស្ថានជាតិអប់រំ បានបង្កើតគណៈកម្មការកែលម្អកម្មវិធីសិក្សាលម្អិត នៅគ្រប់មុខវិជ្ជាសម្រាប់ការបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម(បរិញ្ញាបត្រ+២) ដោយមានការសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ ដូចជាអង្គការខេប(KAPE) ជាដើម។

កម្មវិធីសិក្សាលម្អិតសម្រាប់ការបណ្ដុះបណ្ដាលគរុនិស្សិតកម្រិតឧត្ដម(បរិញ្ញាបត្រ+២)នេះ ត្រូវបានរៀបចំឡើងដោយផ្ដោតទៅលើមុខវិជ្ជារួមនៃឯកទេស(ទស្សនវិជ្ជាអប់រំ ចិត្តវិទ្យា គរុកោសល្យ ស្រាវជ្រាវអប់រំ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀននិងរៀន និងការវាយតម្លៃលទ្ធផលសិក្សា) ដែលតម្រូវឱ្យមានការកែលម្អខ្លឹមសារ និងចំនួនក្រេឌីត។ នៅក្នុងឯកសារនេះ មានវត្ថុបំណងរួម ខ្លឹមសារមេរៀន លទ្ធផលសិក្សារំពឹងទុក និងចំនួនម៉ោងសិក្សាតាមលំដាប់លំដោយ។ គរុនិសិត្សនឹងទទួលបានលទ្ធផលសិក្សាទាំងនេះដើម្បីធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ការបង្រៀននៅតាមគ្រឹះស្ថានសិក្សារបស់ពួកគាត់នាពេលអនាគត។

វិទ្យាស្ថានជាតិអប់រំ សង្ឃឹមទុកថា ឯកសារនេះនឹងបានជាប្រយោជន៍ដ៏សំខាន់ សម្រាប់អ្នកអនុវត្ត ជាពិសេសគរុនិស្សិតដែលទទួលបានការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ ដើម្បីយកចំណេះដឹង និងជំនាញទៅអនុវត្តក្នុងការបង្រៀន ប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ និងជំរុញឱ្យការអប់រំនៅកម្ពុជា មានការអភិវឌ្ឍដូចប្រទេសនានាក្នុងតំបន់ និងលើសកលលោក។

**គណៈកម្មការរៀបចំកម្មវិធីសិក្សាលម្អិត**

I- **គណៈកម្មការគ្រប់គ្រង**

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត ឌី ខាំបូលី | ២- ឯកឧត្តម សៀង សុវណ្ណា | ៣- លោកបណ្ឌិត ឈូក ច័ន្ទធាយ៉ា |
| ៤- លោក ឌី បុណ្ណា | ៥- លោកបណ្ឌិត នូវ វីរ៉ា | ៦- លោកស្រី ប៊ុន សុផានី |
| ៧- លោក ថៃ ហេង | | |

II- **គណៈកម្មការនិពន្ធ និងរៀបរៀង**

**១- ទស្សនវិជ្ជាអប់រំ**

| | | |
|---|---|---|
| ១- លោក ឃិន វណ្ណី | ២- លោក ឡុច ចាន់ថន | ៣- លោក ប៉ូ ប៊ុន្នន |

**២- ចិត្តវិទ្យា**

| | | |
|---|---|---|
| ១- កញ្ញា ហុង ណៃស៊ីម | ២- លោកស្រី កែវ សុបូរិន្ទ | ៣- លោក រិន សុលឿង |
| ៤- លោក តូ សូភី | ៥- លោកស្រី សាន សោយរុក្ខា | ៦- លោកស្រី ហាក់ វណ្ឌនី |

**៣- គរុកោសល្យ**

| | | |
|---|---|---|
| ១- លោក ឡាច ប៊ុនហ៊ាន | ២- លោក ប៉ែន សុម៉ានីន | ៣- លោក ម៉ក់ ចន្ទា |
| ៤- លោកស្រី ប្រាក់ សាណូន | | |

**៤- ស្រាវជ្រាវអប់រំ**

| | | |
|---|---|---|
| ១- លោកស្រី សាំង សុចិន្តា | ២- លោកបណ្ឌិត ចៅ លិន | ៣- លោកបណ្ឌិត ទៀង សោភទ្រា |
| ៤- លោក ផាន់ សុភាព | ៥- លោក រុន នេត្រា | |

**៥- បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការរៀន និងបង្រៀន**

| | | |
|---|---|---|
| ១- លោក ទី ប៉ូលីវស្នី | ២- លោក អ៊ឹម ស៊ុនលី | ៣- លោក លឹម គឹមឃុន |
| ៤- លោក ខាន់ សុផា | | |

**៦- ការវាយតម្លៃលទ្ធផលសិក្សា**

| | | |
|---|---|---|
| ១- លោក ថៃ ហេង | ២- លោកស្រី នូ ចន្នី | ៣- លោក ម៉ន មុនិន្ទ |

III- **គណៈកម្មការត្រួតពិនិត្យ កែលម្អ និងចងក្រងសៀវភៅ**

១- គ្រូឧទ្ទេសទស្សនវិជ្ជាអប់រំ

២- គ្រូឧទ្ទេសចិត្តវិទ្យា

៣- គ្រូឧទ្ទេសគរុកោសល្យ

៤- គ្រូឧទ្ទេសស្រាវជ្រាវអប់រំ

៥- គ្រូឧទ្ទេសបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន

៦- គ្រូឧទ្ទេសវាយតម្លៃលទ្ធផលសិក្សា

| | | |
|---|---|---|
| ៧- លោក ម៉ៅ សារឿន | ៨- លោក គឹម លាង | ៩- លោក ចេង ថុន |
| ១០- លោកបណ្ឌិត អាន វ៉ូប្រាវ | ១១- លោក អ៊ុក ញ៉ាល់ | ១២- លោក អ៊ូ វណ្ណី |
| ១៣- លោក សេង ឡាង | ១៤- លោកស្រីបណ្ឌិត ឡឹយ សុគា | ១៥- កញ្ញា ឆែម គឹមសែន |
| ១៦- លោក ប៊ុនលី ម៉ារឌី | ១៧- លោក ម៉ូត ណារិន | ១៨- តំណាងអង្គការខេប(KAPE) |

# មាតិកា


បុព្វកថា ........ i

អារម្ភកថា ........ ii

គណៈកម្មការ ........ iii

មាតិកា ........ iv

ទស្សនៈអប់រំ ........ ១

ចិត្តវិទ្យា ........ ៩

គរុកោសល្យ ........ ១៧

ស្រាវជ្រាវអប់រំ ........ ២៣

បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន ........ ៣៣

វាយតម្លៃលទ្ធផលសិក្សា ........ ៤៤

# ទស្សនវិជ្ជាអប់រំ

## ១- សេចក្ដីផ្ដើម

សកលលោកមានការរីកចម្រើនគ្រប់វិនាទី និងការប្រកួតប្រជែង ដើម្បីស្វែងរកឧត្ដមភាពនៅលើពិភពលោក ក្នុងបរិបទសកលភាវូបនីយកម្ម ទាមទារឱ្យប្រទេសនីមួយៗខិតខំបង្កើនគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួនឱ្យបានជាអតិបរមា។ ការប្រើប្រាស់ធនធនមនុស្សឱ្យអស់លទ្ធភាពមានសារៈសំខាន់បំផុត ពីព្រោះវាជាកម្លាំងចលករមិនអាចខ្វះបាន ជាពិសេសគុណភាពរបស់គ្រូបង្រៀនដែលបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំ។ ដើម្បីធានាបាននូវគុណភាពអប់រំប្រកបដោយគុណភាពខ្ពស់ និងសមស្របតាមស្តង់ដាថ្នាក់ជាតិ និងអន្តរជាតិ គ្រូឧទ្ទេសសីលធម៌ពលរដ្ឋវិជ្ជានៃវិទ្យាស្ថានជាតិអប់រំបានព្យាយាមសិក្សា និងស្រាវជ្រាវតាមគ្រប់រូបភាពទាំងអស់ ដើម្បីបង្កើតឱ្យបាននូវខ្លឹមសារមេរៀន និងការបង្រៀនទស្សនវិជ្ជាអប់រំសម្រាប់គរុនិស្សិត(បរិញ្ញាបត្រ+២) ឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្ដមដែលប្រកបដោយគុណសម្បត្តិល្អគ្រប់គ្រាន់ដើម្បីបង្រៀនសិស្សរបស់ខ្លួនតាមវិទ្យាល័យនានាទូទាំងព្រះរាជាណាចក្រកម្ពុជាប្រកបដោយគុណភាពខ្ពស់។

ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដោយឈរលើគោលនយោបាយចំនួនពីរគឺទី១ ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន ដើម្បីលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងទី២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីសម្រេចបាននូវវត្ថុបំណងទាំងពីរនេះ មុខវិជ្ជាទស្សនវិជ្ជាអប់រំបានបំពេញតួនាទីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម(បរិញ្ញាបត្រ+២)ឱ្យក្លាយទៅជាគ្រូប្រកបដោយឧត្ដមគតិ ឆន្ទៈ និងប្រឌិតញាណក្នុងការអប់រំសិស្សបន្តទៅថ្ងៃអនាគត។

## ២- គោលបំណង

មុខវិជ្ជាទស្សនវិជ្ជាអប់រំបង្ហាញនូវខ្លឹមសារមេរៀនមួយចំនួនដូចជា សញ្ញាណទូទៅនៃទស្សនវិជ្ជាអប់រំ ប្រវត្តិ ទស្សនវិជ្ជាអប់រំ ទ្រឹស្ដីអំពីការបង្រៀននិងការរៀន ទ្រឹស្ដីទស្សនវិជ្ជាអប់រំ ទស្សនវិជ្ជាអប់រំរបស់ទស្សនវិទូមួយចំនួនរួមមាន សូក្រាត, ប្លាតុង, អារីស្តូត, ចន ឡុក, ហ្សង់ ហ្សាក់ រូស្សូ, ចន ឌូវី និងទស្សនវិជ្ជាអប់រំរបស់ម៉ុនតេសូរី។ ទស្សនវិទូទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទនៃទស្សនវិជ្ជាផ្សេងៗដូចជា ស្ថាបនានិយម ឧត្ដមគតិនិយម និរន្តរភាពនិយម អត្ថិភាពនិយម ប្រតិបត្តិនិយម មនុស្សនិយម អាកប្បកិរិយានិយម អភិរក្សនិយម។ ជារួមក្រុមទាំងនេះត្រូវបានចែកជាពីរផ្នែកគឺទស្សនវិជ្ជាគ្រូមជ្ឈមណ្ឌល និងទស្សនវិជ្ជាសិស្សមជ្ឈមណ្ឌល។ បន្ទាប់ពីសិក្សាលើមុខវិជ្ជានេះចប់គរុនិស្សិត(បរិញ្ញាបត្រ+២) នឹងទទួលបាន៖ អភិវឌ្ឍខ្លួនឯងទៅជាគ្រូបង្រៀនឱ្យមានសមត្ថភាពជំនាញសតវត្សរ៍ទី២១ ដោយផ្ដោតជាសំខាន់ទៅលើចំណេះដឹងវិជ្ជាជីវៈ ជំនាញវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យពេញលក្ខណៈសម្រាប់កសាងសង្គមពុទ្ធិ និងវិបុលភាព។

### ក- វិជ្ជាសម្បទា

- បង្ហាញពីទិដ្ឋភាពទូទៅ និងប្រវត្តិសាស្ត្ររបស់ទស្សនវិជ្ជាអប់រំ។
- ប្រាប់ពីដំណើរការ និងការប្រតិបត្តិរបស់ទ្រឹស្ដីអប់រំមួយចំនួនដូចជា ទ្រឹស្ដីមនុស្សនិយម ទ្រឹស្ដីបរិញាណនិយម ទ្រឹស្ដីស្ថាបនានិយម ទ្រឹស្ដីអាកប្បកិរិយានិយម ទ្រឹស្ដីប្រតិបត្តិនិយម។
- បង្ហាញពីប្រភេទផ្សេងៗនៃការរៀន និងទ្រឹស្ដីនៃការរៀនតាមទ្រឹស្ដីរបស់ទស្សនវិទូមួយចំនួន។

- រៀបរាប់ពីគោលលទ្ធិអប់រំសំខាន់ៗនៃទស្សនវិជ្ជាពិភពលោកដូចជា ទ្រឹស្តីមនោនិយម ទ្រឹស្តីតថនិយម ទ្រឹស្តីប្រតិបត្តិនិយម និងទ្រឹស្តីអត្ថិភាពនិយម។
- ស្រាវជ្រាវពីទ្រឹស្តីអប់រំរបស់ទស្សនវិទូមួយចំនួនដូចជា សូក្រាត, ប្លាតុង, អារីស្តូត, រូស្សូ, ឌូវី, ម៉ុនតេសូរី។
- ពិពណ៌នាពីទម្រង់ធម្មជាតិនៃការអប់រំ ដំណើរការអប់រំ គោលដៅអប់រំ និងកម្មវិធីសិក្សា។

**ខ- បំណិនសម្បទា**

- បង្ហាញពីកន្លែងអប់រំសំខាន់ៗដែលបង្រៀនមនុស្សឱ្យយល់ពីរបៀបនៃការគិតត្រិះរិះពិចារណា។
- ពិភាក្សានិងសិក្សាពីការវិវឌ្ឍនៃការអប់រំតាំងពីសម័យបុរាណរហូតដល់សម័យពន្លឺ។
- ឈ្វេងយល់ពីការទទួលខុសត្រូវរបស់រដ្ឋនីមួយៗ ឬប្រទេសនីមួយៗចំពោះការអប់រំ និងសារៈសំខាន់ប្រជាធិបតេយ្យចំពោះការអប់រំ។
- ពិភាក្សាពីវិធីសាស្ត្រត្រឹមត្រូវក្នុងការរៀននិងការបង្រៀនដោយផ្អែកលើដំណើរការ និងដំណាក់កាលនៃការវិវឌ្ឍរបស់សិស្ស។
- ឆ្លុះបញ្ចាំងគំនិតទស្សនវិទូសំខាន់ៗជាមួយនឹងបរិបទនៃការអប់រំបច្ចុប្បន្ន។
- ច្នៃប្រឌិត និងបង្កើតទស្សនវិជ្ជាអប់រំសម្រាប់អនុវត្តក្នុងការបង្រៀននិងរៀន។

**គ- ចរិយាសម្បទា**

- មានស្មារតីទទួលខុសត្រូវនៅក្នុងការសម្រេចទទួលយកនិងបង្កើតទស្សនវិជ្ជាអប់រំថ្មីសម្រាប់ខ្លួនឯង និងសម្រាប់អង្គភាព។
- បណ្តុះស្មារតីក្នុងការលើកស្ទួយចំពោះការអប់រំណាដែលមានលក្ខណៈវិទ្យាសាស្ត្រ និងប្រកាន់ខ្ជាប់នូវការជ្រើសរើសយកការអប់រំដោយសេរី សមធម៌ និងបរិយាបន្ន។
- មានស្មារតីស្រលាញ់ការសិក្សា និងប្រើប្រាស់នូវទ្រឹស្តីទស្សនវិជ្ជាអប់រំដោយផ្អែកលើ ទ្រឹស្តីពុទ្ធិវិទ្យា ទ្រឹស្តីសីលវិជ្ជា ទ្រឹស្តីតម្លៃ និងទស្សនវិជ្ជាអត្ថិភាពនិយម។
- ទទួលយកការបណ្តុះបណ្តាល ឬការអប់រំសីលធម៌ គុណធម៌ និងការបង្កើតទម្លាប់ដ៏ត្រឹមត្រូវដោយការជំរុញលើកទឹកចិត្តនៅក្នុងការសិក្សា។
- ចេះសម្របខ្លួនទៅតាមបរិបទ បច្ចេកវិទ្យា សេដ្ឋកិច្ច និងពហុវប្បធម៌។
- កសាងខ្លួនឯងឱ្យមានឥទ្ធិពល និងការប្រកួតប្រជែងពីថ្នាក់ជាតិ និងអន្តរជាតិ។
- ឱ្យតម្លៃទៅលើអ្នកសិក្សាដោយគោរពពិពិធភាព។
- ធ្វើការសម្រេចចិត្តដោះស្រាយបញ្ហានានាប្រកបដោយតម្លាភាព យុត្តិធម៌ និងមានសុភវិនិច្ឆ័យ។

## ៣- គោលគំនិតសំខាន់ៗ

- ដំណើរការ គោលបំណង ផែនការអប់រំ និងកម្មវិធីសិក្សានៃការអប់រំ។
- ទ្រឹស្តីនៃការបង្រៀននិងការរៀនដោយផ្អែកតាមទស្សនៈរបស់ទស្សនវិទូមួយចំនួនដូចជា វឌ្ឍនភាពនិយម ស្ថាបនានិយម និរន្តរភាពនិយម ប្រតិបត្តិនិយម អភិរក្សនិយម និងឧត្តមគតិនិយម។
- យល់ដឹងពីដំណាក់កាលនៃការអភិវឌ្ឍរបស់សិស្ស និងការអប់រំ។
- លើកកម្ពស់ការយល់ដឹងពីភាពចំបាច់នៃសេរីភាពនៅក្នុងដំណើរការអប់រំ។
- ការអនុវត្តនូវគោលវិធីសិស្សមជ្ឈមណ្ឌល មែកធាងសំខាន់ៗនៃទស្សនវិជ្ជាអប់រំដោយផ្តោតលើបញ្ញត្តិមូលដ្ឋានគ្រឹះ និងការអនុវត្តជាក់ស្តែង។

- ឆ្លុះបញ្ចាំងគំនិតទស្សនវិទូជាមួយនឹងការអប់រំបច្ចុប្បន្ន។
- ការអភិវឌ្ឍទស្សនវិជ្ជាអាជីពសម្រាប់ការបង្រៀននិងរៀន។

**៤- របាយម៉ោងសិក្សា**

របាយម៉ោងសិក្សានៃមុខវិជ្ជាទស្សនវិជ្ជាអប់រំត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| មុខវិជ្ជា | រយៈពេលសិក្សា |
|---|---|
| ទស្សនវិជ្ជាអប់រំ | **២ ក្រេឌីត ស្មើ ៣០ ម៉ោងសិក្សា** |

**៥- ការណែនាំអនុវត្ត**

ដើម្បីអនុវត្តការបង្រៀនលើមុខវិជ្ជានេះឱ្យបានជោគជ័យគ្រូបង្រៀនមុខវិជ្ជានេះគប្បីត្រូវ៖

- ឱ្យគរុនិស្សិតក្តាប់បានពីចំណុចគន្លឹះរបស់មេរៀនតាមរយៈការប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការរៀននិងបង្រៀន ជំរុញការសិក្សាតាមបែបសកម្មតាមរយៈការងារជាបុគ្គល ជាដៃគូ ជាក្រុម និងការស្រាវជ្រាវឯកសារជំនួយផ្សេងៗ។
- សម្របសម្រួលគរុនិស្សិតក្នុងការក្តាប់បាននូវខ្លឹមសារមេរៀនដោយធ្វើការវិភាគស្ថានភាព និងការពិភាក្សារកដំណោះស្រាយដើម្បីទទួលបានទាំងចំណេះ ជំនាញ និងឥរិយាបថ។

**៦- ការវាយតម្លៃ**

ការវាយតម្លៃគឺជាចំណុចសំខាន់ណាស់នៅក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាទទួលបានធៀបទៅនឹងវត្ថុបំណងមេរៀន ឬចំណុចអប្បរមានៃចំណេះដឹងរបស់គរុនិស្សិតដែលគួរទទួលបានបន្ទាប់ពីបានបញ្ចប់ចំណុចនៃការសិក្សានីមួយៗ និងបញ្ចប់មុខវិជ្ជា។ ការវាយតម្លៃទាំងនោះត្រូវរួមមាន៖

- កិច្ចការស្រាវជ្រាវ
- កិច្ចការក្រុម និងឡើងធ្វើបទបង្ហាញ
- ការសួរសំណួរ ការពិភាក្សា ការប្រឡង និងការធ្វើគម្រោងស្រាវជ្រាវជាដើម។

**៧- តារាងកម្មវិធីសិក្សាលម្អិត**

| **ខ្លឹមសារមេរៀន** | **លទ្ធផលរំពឹងទុក** | **ម៉ោង** |
|---|---|---|
| **មេរៀនទី១ សញ្ញាណទូទៅនៃទស្សនវិជ្ជាអប់រំ**<br>១.១ តួអង្គប្រវត្តិសាស្ត្រសំខាន់ៗ<br>១.២ គោលបំណងនៃការអប់រំ<br>១.៣ ការបង្រៀន, ការរៀន និងកម្មវិធីសិក្សា<br>១.៤ ចំណុចសំខាន់ៗដែលអ្នកអប់រំគួរយល់ដឹងអំពីទស្សនវិជ្ជាអប់រំ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីមុខវិជ្ជាសំខាន់ៗដែលរួមចំណែកក្នុងការអប់រំ៖ ទ្រឹស្តីពុទ្ធិ ទ្រឹស្តីសីលវិជ្ជា ទ្រឹស្តីអស្តិរូបវិជ្ជា ទ្រឹស្តីតក្កវិជ្ជា ទ្រឹស្តីតម្លៃ។<br>**បំណិនសម្បទា**<br>- ឈ្វេងយល់ពីសាលារៀនសំខាន់ៗដែលបង្រៀនពីរបៀបគិតនៅក្នុងទស្សនវិជ្ជា។<br>**ចរិយាសម្បទា**<br>- មានស្មារតីទទួលខុសត្រូវចំពោះការកំណត់យកទស្សនវិជ្ជាអប់រំផ្ទាល់ខ្លួន។ | ១.៥ ម៉ោង |

| | | |
|---|---|---|
| **មេរៀនទី២ ប្រវត្តិ និងទស្សនវិជ្ជាអប់រំ**<br>២.១ ប្រវត្តិនៃការអប់រំ<br>២.២ ក្រិកបុរាណសម័យ និងចក្រភពរ៉ូមៈ ការអប់រំឈានចូលទៅដល់អឺរ៉ុបខាងលិច<br>២.៣ ការដួលរលំចក្រភពរ៉ូម និងយុគសម័យងងឹត<br>២.៤ ពេលវេលានៃការផ្លាស់ប្តូរៈ សម័យបុនភព និងកំណែទម្រង់<br>២.៥ សតវត្សរ៍ទី១៨ និងសម័យក្រោយៈយុគសម័យពន្លឺ ឬសម័យវិចារណញ្ញាណ | **ចំណេះដឹង**<br>- ពណ៌នាអំពីប្រវត្តិសាស្រ្តទស្សនវិជ្ជាអប់រំនៅបស្ចឹមប្រទេសចាប់តាំងពីក្រិកបុរាណសម័យរហូតមកដល់យុគសម័យពន្លឺ។<br>**បំណិនសម្បទា**<br>- បង្ហាញអំពីគោលការណ៍អប់រំនៅក្រិកបុរាណសម័យ, យុគសម័យងងឹត, សម័យបុនភព និងសម័យវិចារណញ្ញាណ។<br>**ចរិយាសម្បទា**<br>- ចូលរួមលើកកម្ពស់ការអប់រំដែលមានលក្ខណៈត្រឹមត្រូវតាមបែបតក្កវិជ្ជា។ | ១.៥ ម៉ោង |
| **មេរៀនទី៣ ទ្រឹស្តីអំពីការបង្រៀននិងរៀន**<br>៣.១ តើការរៀនមានន័យដូចម្តេច?<br>៣.២ ប្រភេទផ្សេងគ្នានៃការរៀន<br>៣.៣ ការអប់រំមានន័យថាជាការរីកចម្រើន ឬការលូតលាស់<br>៣.៤ តើការបង្រៀនមានន័យដូចម្តេច ?<br>៣.៥ ទ្រឹស្តីនៃការរៀន និងការតម្រង់ទិសផ្លូវចិត្ត | **ចំណេះដឹង**<br>- កំណត់និយមន័យការបង្រៀននិងរៀន និងប្រាប់ពីប្រភេទនៃការរៀន។<br>**បំណិនសម្បទា**<br>- វែកញែកអំពីទ្រឹស្តីនៃការរៀនដូចជាៈ ទ្រឹស្តីស្ថាបនានិយម, ទ្រឹស្តីមនុស្សនិយម, ទ្រឹស្តីអាកប្បកិរិយានិយម, ទ្រឹស្តីបរិញ្ញាណនិយម, ទ្រឹស្តីប្រតិបត្តិនិយម។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីធ្វើសកម្មភាពនៅក្នុងការរៀនសូត្រប្រកបដោយសេរីអាផ្ជា។ | ៣ ម៉ោង |
| **មេរៀនទី៤ ទ្រឹស្តីទស្សនវិជ្ជាអប់រំ**<br>៤.១ ទស្សនវិស័យនៃទស្សនវិជ្ជាអប់រំ<br>៤.២ គោលលទ្ធិអប់រំសំខាន់ៗនៃទស្សនវិជ្ជាពិភពលោក<br>៤.២.១ ទ្រឹស្តីមនោនិយម<br>៤.២.២ ទ្រឹស្តីតថនិយម<br>៤.២.៣ ទ្រឹស្តីប្រតិបត្តិនិយម<br>៤.២.៤ ទ្រឹស្តីអត្ថិភាពនិយម<br>៤.៣.៥ ទ្រឹស្តីនិរន្តរភាពនិយម<br>៤.៣.៦ ទ្រឹស្តីសារជាតិនិយម<br>៤.៣.៧ ទ្រឹស្តីវឌ្ឍនភាពនិយម<br>៤.៣.៨ ទ្រឹស្តីស្ថាបនាសង្គមឡើងវិញនិយម | **ចំណេះដឹង**<br>- រៀបរាប់ពីទិដ្ឋភាពទូទៅ និងមែកធាងរងនៅក្នុងទស្សនវិជ្ជាអប់រំ។<br>**បំណិនសម្បទា**<br>- ឈ្វេងយល់អំពីគោលគំនិតអប់រំនៅក្នុងទ្រឹស្តីធំៗចំនួន៤គឺៈ ទ្រឹស្តីមនោនិយម ទ្រឹស្តីតថនិយម, ទ្រឹស្តីប្រតិបត្តិនិយម និង ទ្រឹស្តីអត្ថិភាពនិយម។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ការប្រតិបត្តិនូវគោលគំនិតអប់រំដែលនាំទៅដល់វឌ្ឍនភាពរបស់មនុស្សក៏ដូចជាសង្គមជាតិ។ | ៣ ម៉ោង |

| | | |
|---|---|---|
| **មេរៀនទី៥ ទស្សនវិជ្ជាអប់រំរបស់ សូក្រាត**<br>៥.១ តើអ្នកណាដែលត្រូវទទួលបានការអប់រំ?<br>៥.២ វិធីសាស្ត្របង្រៀនរបស់សូក្រាត<br>៥.៣ ការរិះគន់វិធីសាស្ត្រសូក្រាត<br>៥.៤ ការអប់រំដែលគ្មានគ្រូ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីទ្រឹស្តីអប់រំរបស់សូក្រាតស្តីអំពីការអប់រំដែលមិនចាំបាច់មានគ្រូ។<br>**បំណិនសម្បទា**<br>- វែកញែកពីវិធីសាស្ត្របង្រៀនតាមបែបសូក្រាត និងរិះគន់កែលម្អចំណុចខ្វះខាតមួយចំនួន។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្រលាញ់ការស្វ័យសិក្សា (ការរៀន) ដោយការស្គាល់ខ្លួនឯង។ | ៣ ម៉ោង |
| **មេរៀនទី៦ ទស្សនវិជ្ជាអប់រំរបស់ ប្លាតុង**<br>៦.១ សង្គមក្រិកដំបូង<br>៦.២ សទិសភាពបុគ្គល និងសង្គមរបស់ប្លាតុង<br>៦.៣ ទស្សនៈអប់រំរបស់ប្លាតុង<br>៦.៤. កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីទស្សនវិជ្ជាអប់រំចង់កែប្រែសង្គមតាមរយៈស្នាដៃ"សាធារណៈរដ្ឋ"។<br>**បំណិនសម្បទា**<br>- វែកញែកអំពីមុខងារនៃការអប់រំ, រដ្ឋនិងការអប់រំ, ដំណើរការនៃការអប់រំ, កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់នូវការអប់រំគុណធម៌ និងស្រឡាញ់ការបង្កើតទម្លាប់ត្រឹមត្រូវនៅក្នុងការអប់រំ។ | ៣ ម៉ោង |
| **មេរៀនទី៧ ទស្សនវិជ្ជាអប់រំរបស់ អារីស្តូត**<br>៧.១ បញ្ញត្តិនៃការអប់រំ<br>៧.២ គោលបំណង ឬគោលដៅនៃការអប់រំ<br>៧.៣ ការផ្តល់ពុទ្ធិ(ចំណេះដឹង)<br>៧.៤ កម្មវិធីសិក្សា<br>៧.៥ ដំណាក់កាលនៃការអប់រំ<br>៧.៦ គ្រូ និងសិស្ស<br>៧.៧ ការអប់រំ និងរដ្ឋ<br>៧.៨ វិធីសាស្ត្របង្រៀនរបស់អារីស្តូត<br>៧.៩ អារីស្តូត និងតថនិយម<br>៧.១០ លក្ខណៈដូចគ្នារវាង អារីស្តូត និងប្លាតុង | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យពីការអប់រំ, ការផ្តល់ពុទ្ធិ និងគោលបំណងនៃការអប់រំ។<br>**បំណិនសម្បទា**<br>- បង្ហាញពីកម្មវិធីសិក្សានិងដំណាក់កាលនៃការអប់រំ និងការទទួលខុសត្រូវរបស់រដ្ឋចំពោះការអប់រំ។<br>**ចរិយាសម្បទា**<br>- មានស្មារតីស្រឡាញ់ការអប់រំតែមួយ និងដូចៗគ្នាសម្រាប់មនុស្សទាំងអស់នៅក្នុងរដ្ឋតែមួយ ឬប្រទេសតែមួយ។ | ៣ ម៉ោង |
| **មេរៀនទី៨ ទស្សនវិជ្ជាអប់រំរបស់ ចន ឡុក**<br>៨.១ ការលើកទឹកចិត្តនិងការបង្កើតធនធានមនុស្ស | **វិជ្ជាសម្បទា**<br>- កំណត់ពីអត្ថន័យក្នុងការអភិវឌ្ឍចរិត | ៣ ម៉ោង |

| | | |
|---|---|---|
| ៨.២ គោលការណ៍នៃការរៀនសូត្រ<br>៨.៣ គោលបំណងនៃកាអប់រំ<br>៨.៤ ផែនការនៃការអប់រំ<br>៨.៥ កម្មវិធីសិក្សារបស់លោក ចន ឡុក | លក្ខណៈនៃការអប់រំដោយផ្អែកទៅលើគុណធម៌។<br>**បំណិនសម្បទា**<br>- ឈ្វេងយល់អំពីវិធីត្រឹមត្រូវនៃការរៀន និងការបង្រៀន, គោលបំណងនៃការអប់រំ, ការទទួលបានការអប់រំខុសៗគ្នាក្នុងសហគមន៍ និងកម្មវិធីសិក្សា។<br>**ចរិយាសម្បទា**<br>- ទទួលស្គាល់ថា សេរីភាព និងការជំរុញលើកទឹកចិត្តជាកត្តាដ៏សំខាន់នៅក្នុងការសិក្សារៀនសូត្រ។ | |
| **មេរៀនទី៩ ទស្សនវិជ្ជាអប់រំរបស់ រូស្សូ**<br>៩.១ ធម្មជាតិមនុស្ស៖ ជាគុដើមដំបូងនៃការអប់រំ<br>៩.២ ការខូចទម្រង់សង្គមធម្មជាតិ<br>៩.៣ ការអប់រំសម្រាប់បុគ្គលនិយម<br>៩.៤ ការអប់រំសម្រាប់ភាពជាពលរដ្ឋ<br>៩.៥ វិធីសាស្ត្របង្រៀនរបស់លោក រូស្សូ<br>៩.៦ គោលបំណងនៃការអប់រំ | **វិជ្ជាសម្បទា**<br>- ពិពណ៌នាអំពីធម្មជាតិរបស់មនុស្ស, ទម្រង់សង្គមធម្មជាតិ និងគោលការណ៍អប់រំអវិជ្ជមាន។<br>**បំណិនសម្បទា**<br>- ឈ្វេងយល់ពីអត្ថន័យនិងគោលបំណងនៃការអប់រំសម្រាប់បុគ្គលនិយម និងការអប់រំសម្រាប់ភាពជាពលរដ្ឋ។<br>**ចរិយាសម្បទា**<br>- ចៀសវាងការអប់រំដែលមានលក្ខណៈបង្ខិតបង្ខំ ហើយចូលរួមការពារនូវការអប់រំដែលផ្អែកលើដំណាក់កាលអភិវឌ្ឍរបស់មនុស្ស។ | ៣ ម៉ោង |
| **មេរៀនទី១០ ទស្សនវិជ្ជាអប់រំរបស់ ចន ឌូវី**<br>១០.១ តើអ្វីជាការអប់រំ?<br>១០.២ គោលដៅនៃការអប់រំ<br>១០.៣ ប្រជាធិបតេយ្យ និងការអប់រំ<br>១០.៤ ទ្រឹស្តី និងជំនឿអំពីការអប់រំ<br>១០.៥ ទ្រឹស្តីបទពិសោធ<br>១០.៦ តួនាទីសាលារៀន<br>១០.៧ ដំណើរការបង្រៀននិងរៀន<br>១០.៨ សាលារៀន ចន ឌូវី | **វិជ្ជាសម្បទា**<br>- កំណត់ពីនិយមន័យការអប់រំ, គោលដៅនៃការអប់រំ, តួនាទីគ្រូបង្រៀន, តួនាទីសាលារៀន និងកម្មវិធីសិក្សា។<br>**បំណិនសម្បទា**<br>- បកស្រាយពីដំណើរការបង្រៀននិងរៀន, ប្រជាធិបតេយ្យនិងការអប់រំ។<br>**ចរិយាសម្បទា**<br>- មានស្មារតីបើកចំហនៅក្នុងបរិយាកាស | ៣ ម៉ោង |

| | | |
|---|---|---|
| ១០.៩ តួនាទីគ្រូបង្រៀន<br>១០.១០ តួនាទីនៃកម្មវិធីសិក្សា<br>១០.១១ វិធីសាស្ត្របង្រៀនរបស់លោក ឌូវី | នៃការគិត និងធ្វើសកម្មភាពប្រកបដោយភាពវៃឆ្លាតទៅតាមវិធីផ្សេងៗគ្នា។ | |
| **មេរៀនទី១១ ទស្សនវិជ្ជាអប់រំរបស់ម៉ុនតេសូរី**<br>១១.១ ជីវប្រវត្តិ និងបុគ្គលិកលក្ខណៈ<br>១១.២ ស្នាដៃអប់រំរបស់ម៉ុនតេសូរី<br>១១.៣ វិធីសាស្ត្ររបស់ម៉ុនតេសូរី<br>១១.៣.១ ម៉ុនតេសូរី ជាគ្រូពេទ្យ និងជាអ្នកអប់រំ<br>១១.៣.២ ជាអ្នកទ្រឹស្តីអប់រំ និងការអនុវត្ត<br>១១.៣.៣ ដំណើរការអប់រំ<br>១១.៣.៤ ដំណាក់កាលនៃការអភិវឌ្ឍ<br>១១.៣.៥ កម្មវិធីសិក្សារបស់ម៉ុនតេសូរី<br>១១.៣.៦ ការបង្កើតតម្លៃនិងលក្ខណៈនៃការអប់រំ | **វិជ្ជាសម្បទា**<br>- ពិពណ៌នាពីសាលារៀនម៉ុនតេសូរី និងអន្តរកម្មរបស់អ្នករៀនដែលអាចសម្របខ្លួនបានទៅនឹងបរិយាកាសជុំវិញ។<br>**បំណិនសម្បទា**<br>- បង្ហាញពីដំណើរការអប់រំ ដំណាក់កាលសំខាន់ៗនៃការអភិវឌ្ឍរបស់ម៉ុនតេសូរី។<br>**ចរិយាសម្បទា**<br>- មានការទទួលខុសត្រូវផ្នែកសីលធម៌, គោរពវិន័យ, ម្ចាស់ការលើខ្លួនឯងក្នុងការរៀន និងបន្តធ្វើកិច្ចការដោយក្តីរីករាយ។ | ៣ ម៉ោង |

## ៨- ឯកសារយោង

### ក-ឯកសារជាភាសាខ្មែរ


- ឡុច ចាន់ថន, ឃិន វណ្ណី, បាន កក្កដា. (២០២២). ទ្រឹស្តី និងគំនិតទស្សនវិទូ, ភ្នំពេញ, វិទ្យាស្ថានជាតិអប់រំ, បោះពុម្ពផ្សាយលើកទី១.
- ក្រុមសាស្ត្រាចារ្យទស្សនវិជ្ជា. (២០២០). វចនានុក្រមទស្សនវិជ្ជាអក្សហ៊្វដ អង់គ្លេស-ខ្មែរ, ភ្នំពេញ.
- ក្លាន់ ធុល. (២០២០). ទស្សនវិជ្ជាអប់រំ, ភ្នំពេញ, បោះពុម្ពផ្សាយលើកទី១.
- ស៊ន សេងហុក, ឡុច ចាន់ថន, សំ សែន. (២០២០). ទស្សនវិជ្ជាអប់រំ, ភ្នំពេញ, វិទ្យាស្ថានជាតិអប់រំ.
- អ៊ុន លាង. (២០០៥). ទស្សនវិជ្ជាអប់រំ, ភ្នំពេញ, បោះពុម្ពផ្សាយលើកទី១.


### ខ-ឯកសារជាភាសាបរទេស


- Amélie Oksenberg Rorty. (1998). Philosophers On Education, Routledge, First edition.
- John Dewey. (2004). Democracy and Education, Indian edition.
- Lillard, Paula Polk. (1997). Montessori in the Classroom, Schocken Books Inc.
- Nel Noddings. (1998). Philosophy and Education, Stanford University, First edition.
- R.S.Peters. (2010). John Dewey reconsidered, Routledge, First edition.
- Gerald Lee Gutek. (2004). The Montessori Method, Rowman & Littlefield Publishers.
- Harvey Siegel. (2009). Introduction: Philosophy of Education and Philosophy, Oxford.
- Richard Baily. (2010). The Philosophy and Education: An Introduction, Bloomsbury Academic, First edition.
- William C. Bagley, John A. H. Keith. (1924). An Introduction to Teaching, Macmillan Company, First edition.
- Morgan K. Williams. (2017). John Dewey in the 21st Century, University of West Florida, Journal of Inquiry & Action in Education.
- Angeline Stoll Lillard. (2005). Montessori: The Science Behind the Genius, Oxford University

Press, Inc.
- Robert R. Rusk, James Scotland. (1979). The Doctrines of the Great Educators, St. Martin's Press. Fifth edition.
- Paula Polk Lillard. (1972). Montessori: A modern approach, New York.
- Yogendra K. Sharma. (2002). The Doctrines of the Great Western Educators, Kanishka Publishers. First edition.
- Peter M Collins. (1976). Rousseau's Philosophy (or Philosophies?) of Education, The Irish Journal of Education.
- Randall Curren. (2003). A Companion to the Philosophy of Education, Blackwell Publishing Ltd, First edition.
- Joanna Haynes, Ken Gale, Melanie Parker. (2015). Philosophy and Education, Routledge, First edition.
- Christopher Winch and John Gingell. (2008). Philosophy and Education, Routledge, Second edition.

Paul H. Hirst and Patricia White. (1998). Philosophy and Education, Routledge, First edition.

Moore, B. N., & Parker, R. (2007). Critical Thinking, United State of America: New York, McGraw-Hill, 8th edition.

William Harrison Woodward. (1904). Desiderius Erasmus concerning the Aim and Method of Education, Cambridge.

# ចិត្តវិទ្យា

## ១- សេចក្តីផ្តើម

ការរីកចំម្រើនយ៉ាងឆាប់រហ័សឥតឈប់ឈរ និងការប្រកួតប្រជែងស្វែងរកឧត្តមភាពនៅលើពិភពលោក ក្នុងបរិបទសកលភាវូបនីយកម្ម ទាមទារឲ្យប្រទេសនីមួយៗខិតខំបង្កើនគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួនឲ្យបានជាអតិបរមា។ ការប្រើប្រាស់ធនធនមនុស្សប្រកបដោយគុណភាព មានសារៈសំខាន់បំផុត ពីព្រោះវាជាកម្លាំងចលករមិនអាចខ្វះបាន។ ការធានាគុណភាពអប់រំដោយការធ្វើអធិការកិច្ច ការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិ និងអន្តរជាតិ ត្រូវបានគេទទួលស្គាល់ និងឲ្យតម្លៃខ្ពស់ថាមានតួនាទី និងភារកិច្ចដ៏សំខាន់ ក្នុងការរួមចំណែកអភិវឌ្ឍធនធនមនុស្ស និងផ្តល់វិភាគទាន ដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍ សង្គមជាតិ និងសកលលោក។

ក្រសួងអប់រំ យុវជន និងកីឡា ជាក្រសួងអាទិភាពមួយរបស់រាជរដ្ឋាភិបាលដែលមានចំនួនបុគ្គលិកបម្រើការងារច្រើនជាងគេ។ ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍធនធនមនុស្ស នៅក្រសួងអប់រំ យុវជន និងកីឡា មានសារៈសំខាន់ណាស់ ព្រោះមិនត្រឹមតែជួយធ្វើសនិទានកម្មធនធនមនុស្សក្នុងវិស័យប៉ុណ្ណោះទេ គឺថែមទាំងរួមចំណែកជាមួយ រាជរដ្ឋាភិបាល ក្នុងការធ្វើឱ្យគោលនយោបាយកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលអាចអនុវត្តបានដោយល្អប្រសើរ និងមានចីរភាព ពិសេសការប្រើប្រាស់ធនធនមនុស្ស ក្នុងមុខងារសាធារណៈ។ ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាលក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ដោយឈរគោលនយោបាយចំនួន២គឺ (១) ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន ដើម្បីលើកកម្ពស់ឱកាសក្នុងសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នានិង(២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវគោលនយោបាយទាំងពីរខាងលើ ការបណ្តុះបណ្តាលគរុនិស្សិតទូទៅនៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តមដែលពាក់ព័ន្ធនឹងក្របខណ្ឌធានាគុណភាព គឺជាកត្តាដែលមិនអាចខ្វះបាន ព្រោះក្រសួងបាននឹងកំពុងយកចិត្តទុកដាក់ទៅលើការធ្វើកំណែទម្រង់វិស័យអប់រំឆ្ពោះទៅរកគុណភាពដើម្បីលើកស្ទួយ ប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងជាប្រទេសអភិវឌ្ឍនាឆ្នាំ២០៥០។

## ២- គោលបំណង

មុខវិជ្ជាចិត្តវិទ្យារួមចំណែកផ្តល់ឱ្យគរុនិស្សិតទូទៅនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមសម្រាប់ធានាគុណភាពអប់រំនឹងមានបង្ហាញពីនិន្នាការអប់រំសកលលោកក៏ដូចជាច្បាប់របស់បាតុភូតចិត្ត ទ្រឹស្តីនៃចិត្តវិទ្យា និងការណែនាំភ្ជាប់នឹងទ្រឹស្តីចំពោះការអនុវត្តដាក់ស្តែងក្នុងថ្នាក់រៀន និងក្នុងជីវភាពរស់នៅ ក្នុងគោលបំណងធ្វើឱ្យការរៀន និងការបង្រៀនកាន់តែមានគុណភាព ដើម្បីឆ្លើយតបទៅនឹងបរិបទថ្មីនៃការអប់រំក្នុងសម័យសកលភាវូបនីយកម្ម។ ដូច្នេះ ក្រោយពីការសិក្សាលើមុខវិជ្ជានេះចប់ អ្នកសិក្សានឹងអាចៈ

### ក- វិជ្ជាសម្បទា

- បកស្រាយបានពីទិដ្ឋភាពទូទៅនៃចិត្តវិទ្យា និងតួនាទីរបស់ចិត្តវិទ្យាអប់រំដោយផ្តោតលើ ការរៀន និងការបង្រៀនក្នុងសម័យឌីជីថល នៃសតវត្សទី២១។
- បកស្រាយបានពីបញ្ញតិ និងទ្រឹស្តីចម្បងៗនៃការរៀន លំនាំចំណេះដឹង ការអភិវឌ្ឍបុគ្គលិកលក្ខណៈ និងលក្ខណៈពិសេសរបស់វ័យជំទង់ ការអភិវឌ្ឍអត្តសញ្ញាណ និងសីលធម៌របស់សិស្ស និងគោលការណ៍អនុវត្តក្នុងថ្នាក់រៀន បញ្ហាសុខភាពផ្លូវចិត្ត រួមជាមួយនឹងរបៀបអន្តរាគមន៍ជាមូលដ្ឋានក្នុង

តួនាទីជាគ្រូបង្រៀន។

**ខ- បំណិនសម្បទា**

- កំណត់បាននូវសារៈសំខាន់នៃចិត្តវិទ្យាក្នុងការអនុវត្តក្នុងវិស័យអប់រំ។
- អនុវត្ត និងប្រើប្រាស់ចំណេះដឹងទាក់ទងនឹងចិត្តវិទ្យាទូទៅ និងចិត្តវិទ្យាអប់រំក្នុងការងារប្រចាំថ្ងៃប្រកបដោយភាពច្នៃប្រឌិតដើម្បីបង្កើនគុណភាពនៃការរៀន និងបង្រៀនរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព ឆ្លើយតបនឹងគុណតម្លៃស្នូលនៃគ្រូបង្រៀនក្នុងសតវត្សទី២១។
- រៀបចំកម្រងសំណួរវាយតម្លៃសមិទ្ធផលសិក្សារបស់សិស្សឱ្យបានសមស្រប ។

**គ- ចរិយាសម្បទា**

- ឱ្យតម្លៃខ្ពស់ទៅលើទ្រឹស្តីនៃចិត្តវិទ្យា និងចូលរួមគ្រប់សកម្មភាពសិក្សា ។
- ឆ្លុះបញ្ចាំងខ្លួនឯង និងរៀបចំចរិយាសម្បទាឱ្យស្របទៅនឹងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។
- យកទ្រឹស្តីចិត្តវិទ្យាទៅអនុវត្តក្នុងជីវភាពរស់នៅនិងក្នុងលំនាំនៃការបង្រៀនប្រកបដោយប្រសិទ្ធភាពនៅមធ្យមសិក្សា។

## ៣- គោលគំនិតសំខាន់ៗ

- ទិដ្ឋភាពទូទៅនៃចិត្តវិទ្យា បាតុភូតចិត្ត មុខងារប្រព័ន្ធប្រសាទ និងលំនាំចំណេះដឹង។
- ការអភិវឌ្ឍបុគ្គលិកលក្ខណៈវ័យជំទង់ បញ្ហាសុខភាពផ្លូវចិត្ត និងការរបៀបអន្តរាគមន៍ក្នុងតួនាទីជាគ្រូបង្រៀន និងរចនាសម្ព័ន្ធបុគ្គលិកលក្ខណៈ។
- ការអភិវឌ្ឍអត្តសញ្ញាណ សីលធម៌របស់សិស្ស និងគោលការណ៍អនុវត្តក្នុងថ្នាក់រៀន។
- ការប្រមូលផ្តុំទ្រឹស្តីចម្បងៗនៃការរៀនក្នុងចិត្តវិទ្យាអប់រំសព្វថ្ងៃ និងតួនាទីរបស់ចិត្តវិទ្យាអប់រំ។

## ៤- របាយម៉ោងសិក្សា

របាយម៉ោងសិក្សា នៃមុខវិជ្ជាចិត្តវិទ្យាត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| មុខវិជ្ជា | រយៈពេលសិក្សា |
|---|---|
| **ចិត្តវិទ្យា** | **៣ ក្រេឌីត ស្មើ ៤៥ ម៉ោងសិក្សា** |

## ៥- ការណែនាំអនុវត្ត

ដើម្បីអនុវត្តការបង្រៀនលើមុខវិជ្ជានេះឱ្យបានជោគជ័យគ្រូបង្រៀនគប្បី៖

- ឱ្យគរុនិស្សិតក្តាប់បានពីចំណុចគន្លឹះសំខាន់ៗនៃមេរៀនតាមរយៈការប្រើគោលវិធីសិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្រថ្មីៗក្នុងការបង្រៀន។
- ជំរុញការសិក្សាតាមបែបសកម្ម តាមរយៈការងារជាបុគ្គល ជាដៃគូ ជាក្រុម និងការស្រាវជ្រាវឯកសារដើម្បីបង្កើតស្នាដៃផ្ទាល់ខ្លួន។
- សម្របសម្រួលគរុនិស្សិត ឱ្យក្តាប់បាននូវខ្លឹមសារមេរៀន ដើម្បីទទួលបានទាំងចំណេះ ជំនាញ និងចរិយាសម្បទាស្របតាមគោលដៅកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៦- ការវាយតម្លៃ

ការវាយតម្លៃ គឺជាចំណុចសំខាន់ ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាទទួលបាន ធៀបទៅនឹងវត្ថុបំណងនៃមេរៀន ឬចំណុចអប្បរមានៃចំណេះអ្នកសិក្សាដែលគួរទទួលបានបន្ទាប់ពីបានបញ្ចប់ចំណុចនៃការសិក្សានីមួយៗ

និងបញ្ចប់មុខវិជ្ជា។

- ✓ ការវាយតម្លៃតាមដំណាក់កាល (៣០%)
- ✓ វិន័យ និងឥរិយាបថ (១៥%)
- ✓ សរសេររបាយការណ៍គម្រោង (៣០%)
- ✓ ប្រឡងបញ្ចប់ (២៥%)

## ៧- តារាងកម្មវិធីសិក្សាលម្អិត

| ខ្លឹមសារ | លទ្ធផលសិក្សា | ម៉ោង |
|---|---|---|
| **ជំពូកទី ១ សញ្ញាណទូទៅស្តីពីចិត្តវិទ្យា** | | ១៣ ម៉ |
| **១.១. ចិត្តវិទ្យា និងមូលដ្ឋានសរីរៈនៃបាតុភូតចិត្ត**<br>១.១.១ និយមន័យនៃចិត្តវិទ្យា<br>១.១.២ ធម្មជាតិនៃបាតុភូតចិត្ត<br>១.១.៣ ចំណែកថ្នាក់នៃបាតុភូតចិត្ត<br>១.១.៤ សារៈសំខាន់នៃចិត្តវិទ្យាក្នុងការអប់រំ<br>១.១.៥ មូលដ្ឋានសរីរៈនៃបាតុភូតចិត្ត<br>១.១.៦ ទំនាក់ទំនងរវាង ចិត្តវិទ្យានិងសរីរៈវិទ្យា<br>១.១.៧ ចំណាំងរបស់តថភាពសត្យានុម័ត<br>១.១.៨ សញ្ញាណសង្ខេបលើទ្រង់ទ្រាយ និងមុខងារ របស់ប្រព័ន្ធសរសៃប្រសាទ | **វិជ្ជាសម្បទា**<br>- បកស្រាយពន្យល់ពីបញ្ញត្តិនៃចិត្តវិទ្យា ពីចំណែកថ្នាក់នៃបាតុភូតចិត្ត និងពីអត្ថប្រយោជន៍របស់ចិត្តវិទ្យាចំពោះសង្គម ជាពិសេសចំពោះការអប់រំសិស្ស នៅមធ្យមសិក្សា។<br>- ពន្យល់ពីទំនាក់ទំនងរវាងបាតុភូតចិត្ត និងសរីរៈវិទ្យា ពីរ៉េផ្លិច និងពីច្បាប់ប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស។<br>**បំណិនសម្បទា**<br>- កំណត់ច្បាស់នូវវិធីជាច្រើនក្នុងការសង្កេតទៅលើបាតុភូតចិត្តរបស់មនុស្ស និងរកឃើញភាពប្លែកគ្នារវាងលំនាំចិត្ត សភាពចិត្ត និងលក្ខណៈចិត្តរបស់មនុស្ស។<br>- កំណត់ច្បាស់ពីមូលដ្ឋានសរីរៈដែលបង្កើតនូវបាតុភូតចិត្តរបស់មនុស្ស។<br>- រកឃើញភាពខុសគ្នារវាងរ៉េផ្លិចឥតលក្ខខ័ណ្ឌ និងរ៉េផ្លិចមានលក្ខខ័ណ្ឌ និងកំណត់ច្បាស់នូវច្បាប់នីមួយ ៗរបស់សកម្មភាពប្រព័ន្ធសរសៃប្រសាទ។<br>**ចរិយាសម្បទា**<br>- ប្រែក្លាយខ្លឹមសារមេរៀនទៅជាបទពិសោធន៍ដើម្បីអនុវត្តនៅក្នុងជីវភាពរស់នៅ និងក្នុងលំនាំនៃការបង្រៀនប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ | ៦ ម៉ |

| | | |
|---|---|---|
| | - ជឿជាក់ និងប្រកាន់យកនូវគំនិតជាវិជ្ជមានចំពោះដំណើរការប្រព្រឹត្តទៅនៃមុខងារផ្លូវចិត្ត និងជីវសាស្ត្រខួរក្បាល រួមជាមួយការរៀនពេញមួយជីវិត។<br>- ឱ្យតម្លៃទៅលើខ្លឹមសារមេរៀន និងអនុវត្តបានត្រឹមត្រូវនៅក្នុងដំណើរការនៃការបង្រៀនសិស្ស យោងទៅតាមលក្ខណៈរ៉ែផ្លិចនិងមុខងារខួរក្បាល។ | |
| **១.២ លំនាំចំណេះដឹង**<br>១.២.១ ពុទ្ធិឥន្រ្ទីយ៍<br>១.២.២ ពុទ្ធិវិចារ<br>១.២.៣ លំនឹក | **វិជ្ជាសម្បទា**<br>- បកស្រាយពន្យល់ពីលំនាំក្នុងការទទួលបានចំណេះដឹង របស់សិស្ស លំនាំក្នុងការក្តាប់យកព័ត៌មាន និងចំណេះដឹងរបស់សិស្ស។<br>- ពន្យល់ពីទំនាក់ទំនងរវាងពុទ្ធិឥន្រ្ទីយ៍ ពុទ្ធិវិចារ និងការក្តាប់យកព័ត៌មានរបស់សិស្ស។<br>**បំណិនសម្បទា**<br>- កំណត់ច្បាស់ពីលំនាំចំណេះដឹង និងរកឃើញភាពខុសប្លែកគ្នារវាងពុទ្ធិឥន្រ្ទីយ៍ ពុទ្ធិវិចារ និងលំនឹក។<br>- អនុវត្តចំណេះដឹងដែលបានមកពីមេរៀននេះដើម្បីជំនួយដល់សកម្មភាពបង្រៀន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃលើការអនុវត្តចំណេះនៃលំនាំក្នុងការកសាងចំណេះដឹង និងទុកជាបទពិសោធន៍អប់រំសិស្សកាន់តែប្រសើរ។ | ៧ ម៉ |
| **ជំពូកទី២៖ ការអភិវឌ្ឍបុគ្គលិកលក្ខណៈ លក្ខណៈពិសេសរបស់វ័យជំទង់ និងការអភិវឌ្ឍអត្តសញ្ញាណ និងសីលធម៌** | | ២០ ម៉ |
| **២.១ ការអភិវឌ្ឍបុគ្គលិកលក្ខណៈ**<br>២.១.១ លក្ខណៈធម្មជាតិរបស់មនុស្ស<br>២.១.២ លំនាំនៃការអភិវឌ្ឍ | **វិជ្ជាសម្បទា**<br>- ពន្យល់បកស្រាយពីធម្មជាតិពិតរបស់មនុស្ស និងកត្តាជះឥទ្ធិពលដល់បុគ្គលិកលក្ខណៈរបស់មនុស្ស។ | ៦ ម៉ |

| | | |
|---|---|---|
| បុគ្គលិកលក្ខណៈ<br>២.១.៣ កត្តាជះឥទ្ធិពលដល់បុគ្គលិកលក្ខណៈ | **បំណិនសម្បទា**<br>- កំណត់ច្បាស់ពីកត្តាដែលជះឥទ្ធិពលដល់អភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្ស។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃទៅលើចំណេះដឹងនៃការស្គាល់ពីបុគ្គលិកលក្ខណៈសិស្ស និងអនុវត្តនៅក្នុងការងារបង្រៀន និងជីវភាពប្រចាំថ្ងៃ។ | |
| **២.២ រចនាសម្ព័ន្ធបុគ្គលិកលក្ខណៈ**<br>២.២.១ ទំនោរ<br>២.២.២ អត្តចរិត<br>២.២.៣ ឫកពា<br>២.២.៤ សម្បទា | **វិជ្ជាសម្បទា**<br>- ពន្យល់បាននូវអត្ថន័យ នៃប្រភេទនីមួយៗរបស់រចនាសម្ព័ន្ធបុគ្គលិកលក្ខណៈ។<br>**បំណិនសម្បទា**<br>- កំណត់ពីលក្ខណៈខុសគ្នានៃរចនាសម្ព័ន្ធបុគ្គលិកលក្ខណៈ។<br>**ចរិយាសម្បទា**<br>- មានសមត្ថភាពបត់បែនក្នុងការបង្រៀន និងគ្រប់គ្រង សិស្សដោយការអនុវត្តខ្លឹមសារនៃរចនាសម្ព័ន្ធបុគ្គលិកលក្ខណៈ<br>- ផ្តល់តម្លៃលើវិសេសភាពរបស់សិស្សនិងប្រែក្លាយចំនុចពិសេសរបស់សិស្សក្នុងការលើកទឹកចិត្តនិងជម្រុញការសិក្សារបស់សិស្ស។ | ៤ ម៉ |
| **២.៣ លក្ខណៈពិសេសរបស់វ័យជំទង់ និងការអភិវឌ្ឍអត្តសញ្ញាណ និងសីលធម៌**<br>២.៣.១ លក្ខណៈពិសេសនៃវ័យជំទង់<br>២.៣.២ ការអភិវឌ្ឍអត្តសញ្ញាណ<br>២.៣.៣ ទ្រឹស្តីចិត្ត និងសញ្ចេតនា<br>២.៣.៤ ការអភិវឌ្ឍសីលធម៌<br>២.៣.៥ ការវិនិច្ឆ័យខាងសីលធម៌ | **វិជ្ជាសម្បទា**<br>- ពន្យល់ពីបំលាស់ប្តូរផ្នែកសរីរាង្គ ចិត្ត គំនិត បញ្ញា ស្មារតី និងបញ្ហាផ្លូវអារម្មណ៍របស់ជំទង់។<br>- ពិពណ៌នាអំពីនិន្នាការទូទៅនិងក្រុមភាពខុសគ្នានៃការអភិវឌ្ឍអត្តសញ្ញាណនិងគំនិតខ្លួនឯង។<br>- ពន្យល់ពីទ្រឹស្តីនៃការអភិវឌ្ឍសីលធម៌រួមបញ្ចូលទាំងទ្រឹស្តី Kohlberg, Gilligan,Nucci, និង Haidt និងរបៀប | ៧ ម៉ |

| | | |
|---|---|---|
| ២.៣.៦ ភាពខុសគ្នានៃភាពសមហេតុផលខាងសីលធម៌<br>២.៣.៧ អាកប្បកិរិយាខាងសីលធម៌ និងឧទាហរណ៍នៃការបន្លំ | ដែលគ្រូអាចដោះស្រាយជាមួយបញ្ហាប្រឈមខាងសីលធម៌ជាមួយសិស្សដែលភូតកុហក។<br>**បំណិនសម្បទា**<br>- រកឃើញនូវភាពខុសប្លែកគ្នានៃការអភិវឌ្ឍផ្នែកសរីរាង្គ ផ្នែកចិត្តគំនិត ផ្នែកសង្គម និងផ្នែកផ្លូវអារម្មណ៍របស់ជំទង់។<br>- វិភាគ និងអនុវត្តការគាំទ្រផ្លូវចិត្តដល់ជំទង់ជាសិស្ស។<br>- បកស្រាយពីការលូតលាស់ផ្នែកចិត្តគំនិតរបស់ជំទង់ជាពិសេសគឺ ការកំណត់អត្តសញ្ញាណ សង្គមនិងសីលធម៌ តាមទ្រឹស្តីអេរិកសុន។<br>- រកឃើញនូវវិធីដែលសមស្របដើម្បីជួយឱ្យជំទង់អភិវឌ្ឍបានពេញលេញផ្នែកផ្លូវចិត្ត។<br>**ចរិយាសម្បទា**<br>- ប្រកាន់យកចរិយាសម្បទាដែលកក់ក្ដៅ និងលើកទឹកចិត្តសិស្ស និងអាណាព្យាបាលឱ្យចូលរួមជួយពង្រឹងជំទង់ឆ្លងផុតនូវការលំបាកនៅក្នុងដំណើរការអភិវឌ្ឍនេះ និងក្លាយទៅជាមនុស្សប្រកបដោយសក្ដានុពល។ | |
| **២.៤ សុខភាពផ្លូវចិត្ត**<br>២.៤.១ សុខភាពផ្លូវចិត្តជំទង់<br>២.៤.២ កំណត់សម្គាល់បញ្ហាផ្លូវចិត្តទូទៅដែលអាចកើតមានឡើងចំពោះជំទង់<br>២.៤.៣ របៀបក្នុងការគាំទ្រផ្លូវចិត្តជំទង់ក្នុងតួនាទីជាគ្រូបង្រៀន | **វិជ្ជាសម្បទា**<br>- ពណ៌នាពីទិដ្ឋភាពទូទៅនៃសុខភាពផ្លូវចិត្ត សញ្ញាសម្គាល់បញ្ហាផ្លូវចិត្ត និងកិច្ចអន្តរាគមន៍ទៅកាន់ជំទង់។<br>- កំណត់បានពីបញ្ហាផ្លូវចិត្ត និងរបៀបក្នុងការគាំទ្រផ្លូវចិត្តជំទង់។<br>**បំណិនសម្បទា**<br>- វែកញែកបានពីសញ្ញាសម្គាល់អ្នកដែលមានបញ្ហាផ្លូវចិត្ត និងរបៀបក្នុងការគាំទ្រផ្លូវចិត្តជំទង់។<br>- អនុវត្តរបៀបគាំទ្រផ្លូវចិត្តជំទង់ក្នុងតួនាទី | ៣ ម៉ |

| | | |
|---|---|---|
| | ជាគ្រូបង្រៀន។<br>**ចរិយាសម្បទា**<br>- ចូលរួមស្វែងយល់ពីបញ្ហាផ្លូវចិត្តជំទង់ យកចិត្តទុកដាក់ថែទាំ និងលុបបំបាត់ការរើសអើងចំពោះអ្នកដែលមានបញ្ហាផ្លូវចិត្ត។ | |
| **ជំពូកទី ៣ ចិត្តវិទ្យាអប់រំ** | | ១២ ម៉ |
| **៣.១ សញ្ញាណទូទៅនៃចិត្តវិទ្យាអប់រំ**<br>៣.១.១ អ្វីជាចិត្តវិទ្យាអប់រំ?<br>៣.១.២ ចិត្តវិទ្យាអប់រំសព្វថ្ងៃ<br>៣.១.៣ តួនាទីរបស់ចិត្តវិទ្យាអប់រំ<br>៣.១.៤ ភាពចម្រុះរបស់សិស្ស<br>៣.១.៥ ទំនាក់ទំនងគ្រូសិស្ស<br>៣.១.៦ ចិត្តរំភើប សញ្ចេតនា និងប្រសិទ្ធនៃការរៀន និងបង្រៀន | **វិជ្ជាសម្បទា**<br>- កំណត់បានពីនិយមន័យនៃចិត្តវិទ្យាអប់រំ<br>- រៀបរាប់ពីតួនាទីរបស់ចិត្តវិទ្យាអប់រំសព្វថ្ងៃ<br>**បំណិនសម្បទា**<br>- រកឃើញពីសារៈសំខាន់ក្នុងការអនុវត្តចិត្តវិទ្យាអប់រំក្នុងការបង្រៀន និងរៀន។<br>- បកស្រាយបានពីភាពចម្រុះ ចិត្តរំភើប សញ្ចេតនា និងទំនាក់ទំនងសិស្សគ្រូក្នុងការអប់រំចិត្តវិទ្យា។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃលើការអនុវត្តចិត្តវិទ្យាអប់រំក្នុងការកសាងសមត្ថភាព និងបទពិសោធន៍អប់រំសិស្សកាន់តែប្រសើរ។ | ៦ម៉ |
| **៣.២ ទ្រឹស្តីនៃការរៀន**<br>៣.២.១ ការបង្រៀន និងការរៀន<br>៣.២.២ ទ្រឹស្តីនៃការរៀនតាមបែបបែបអាកប្បកិរិយានិយម<br>៣.២.៣ ទ្រឹស្តីនៃការរៀនតាមបែបបែបពុទ្ធិនិយម<br>៣.២.៤ ទ្រឹស្តីនៃការរៀនតាមបែបបែបស្ថាបនានិយម<br>៣.២.៥ ទ្រឹស្តីនៃការរៀនតាមបែបបែបសង្គមនិយម<br>៣.២.៦ ទ្រឹស្តីនៃការរៀនតាមបែបបែបមនុស្សនិយម | **វិជ្ជាសម្បទា**<br>- ពន្យល់បានពីបញ្ញតិនៃពាក្យថារៀននិងបង្រៀន។<br>- ពិពណ៌នាអំពីគោលគំនិតរបស់ទ្រឹស្តីនៃការរៀនចំពោះការសិក្សា។<br>**បំណិនសម្បទា**<br>- ញែកឱ្យដាច់រវាងគំរូនៃការអភិវឌ្ឍពុទ្ធិ និងគំរូនៃដំណើរការក្តាប់យកព័ត៌មាន។<br>- អនុវត្តទ្រឹស្តីនៃការរៀននៅក្នុងគោលការណ៍អប់រំ។<br>- ប្រើប្រាស់ និងវិភាគលើចំណេះដឹងនៃទ្រឹស្តីដែលលើកឡើងខាងលើ ដើម្បីបម្រើឱ្យការអប់រំ និងគុណភាពនៃបង្រៀន និងរៀន។ | ៦ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- ឱ្យតម្លៃលើទ្រឹស្តីចម្បងៗ នៃចិត្តវិទ្យាអប់រំ និងប្រកាន់យកនូវគំនិតច្នៃប្រឌិតផ្ទាល់ខ្លួនក្នុងការប្រើប្រាស់ចំណេះដឹងទាំងនេះ ក្នុងការបង្រៀនសិស្ស។ | |

## ៨- ឯកសារយោង


- ចិត្តវិទ្យាទូទៅដោយ បណ្ឌិត ចាន់ រដ្ឋសុផា ឆ្នាំ ២០០៣
- ចិត្តវិទ្យាអប់រំ ដោយ បណ្ឌិត ចាន់ រដ្ឋសុផា ភាគ ១ ឆ្នាំ ២០០៧
- ឯកសារចិត្តវិទ្យា សម្រាប់បំប៉នសមត្ថភាពគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
- ដោយ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ឆ្នាំ ២០០៦
- ចិត្តវិទ្យា ដោយ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ឆ្នាំ ២០០២
- Woolfolk, A. (2016). *Educational psychology* (13th ed.). Pearson Education.
- Myers, D., & Dewall, C. (2016). *Exploring psychology in modules* (10th ed.). New York.
- Eggen, P., & Kauchak, D. (2015). *Educational* Psychology. Pearson Education UK.
- វិទ្យាស្ថានជាតិអប់រំ. (2020). ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាល គ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១). ភ្នំពេញ: វិទ្យាស្ថានជាតិអប់រំ.

# គរុកោសល្យ

## ១- សេចក្តីផ្តើម

ការរីកចម្រើនយ៉ាងឆាប់រហ័សឥតឈប់ឈរ និងការប្រកួតប្រជែង ដើម្បីស្វែងរកឧត្តមភាពនៅលើពិភពលោកក្នុងបរិបទសកលភាវូបនីយកម្មទាមទារឲ្យប្រទេសនីមួយៗខិតខំបង្កើនគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួនឲ្យបានជាអតិបរមា។ ការប្រើប្រាស់ធនធានមនុស្សឲ្យអស់លទ្ធភាពមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះវាជាកម្លាំងចលករមួយដែលមិនអាចខ្វះបាន។ ដើម្បីធានានូវគុណភាពអប់រំតាមរយៈការធ្វើអធិការកិច្ច ការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិ និងអន្តរជាតិ ត្រូវបានគេទទួលស្គាល់ និងឲ្យតម្លៃខ្ពស់ថាមានតួនាទី និងភារកិច្ចដ៏សំខាន់ ក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស និងផ្តល់វិភាគទានដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍សង្គមជាតិ និងសកលលោក។

ក្រសួងអប់រំ យុវជន និងកីឡា ជាក្រសួងអាទិភាពមួយរបស់រាជរដ្ឋាភិបាលដែលមានចំនួនបុគ្គលិកបម្រើការងារច្រើនជាងស្ថាប័នផ្សេងទៀត។ ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅក្រសួងអប់រំ យុវជន និងកីឡាមានសារៈសំខាន់បំផុត ព្រោះមិនត្រឹមតែជួយធ្វើសនិទានកម្មធនធានមនុស្សក្នុងវិស័យអប់រំប៉ុណ្ណោះទេ គឺថែមទាំងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការធ្វើគោលនយោបាយកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលដែលអាចអនុវត្តបានដោយល្អប្រសើរ និងមានចីរភាព ជាពិសេសការប្រើប្រាស់ធនធានមនុស្សក្នុងមុខងារសាធារណៈ។ ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្រសួងអប់រំយុវជននិងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ២០១៨-២០២៣ ដោយឈរលើគោលនយោបាយធំៗ ចំនួន ២គឺ(១)ធានាឲ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុង ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង(២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវគោលនយោបាយទាំងពីរខាងលើ ការបណ្តុះបណ្តាលគរុនិស្សិតទូទៅនៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តមដែលពាក់ព័ន្ធនឹងក្របខណ្ឌធានាគុណភាព គឺជាកត្តាដែលមិនអាចខ្វះបាន ព្រោះក្រសួងបាននឹងកំពុងយកចិត្តទុកដាក់ទៅលើការធ្វើកំណែទម្រង់វិស័យអប់រំឆ្ពោះទៅរកគុណភាពដើម្បីលើកស្ទួយប្រទេសកម្ពុជាឲ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនាឆ្នាំ២០៥០។

## ២- គោលបំណង

មុខវិជ្ជាគរុកោសល្យសម្រាប់គរុនិស្សិតទូទៅនៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម ជានាគុណភាពអប់រំនឹងមានបង្ហាញពីនិន្នាការអប់រំសកលលោកក៏ដូចជាច្បាប់ គោលការណ៍បង្រៀន វិធីសាស្ត្របង្រៀន និងវិធីអប់រំនានាដែលពាក់ព័ន្ធទៅនឹងវិស័យអប់រំ ព្រមទាំងធ្វើការណែនាំផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់រៀនក៏ដូចជាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ក្នុងគោលបំណងធ្វើឲ្យការរៀន និងការបង្រៀនកាន់តែមានគុណភាពល្អប្រសើរដើម្បីឆ្លើយតបទៅនឹងបរិបទថ្មីនៃការអប់រំក្នុងសម័យទំនើប។ ដូច្នេះក្រោយពីការសិក្សាលើមុខវិជ្ជានេះចប់អ្នកសិក្សានឹងអាចៈ

### ក- វិជ្ជាសម្បទា

- បកស្រាយបានអំពីបញ្ហាទូទៅក្នុងការអប់រំសិស្ស ទ្រឹស្តីនៃការបង្រៀននិងរៀន ការអភិវឌ្ឍសីលធម៌ និងចរិយាធម៌។

- ពន្យល់ពីគោលការណ៍គ្រឹះ និងចតុស្តម្ភនៃការអប់រំ
- បង្ហាញពីគោលវិធីបង្រៀន វិធីបង្រៀនប្រកបដោយប្រសិទ្ធភាពនៅសាលារៀនចំណោះទូទៅ
- បកស្រាយពីទំនាក់ទំនងរវាងចិត្តវិទ្យា និងគរុកោសល្យក្នុងការងារបង្រៀន និងអប់រំ។

**ខ- បំណិនសម្បទា**

- ជ្រើសរើសវិធីសាស្ត្របង្រៀនសមស្របតាមខ្លឹមសារនៃមេរៀន
- រៀបចំប្រភេទសំណួរបានច្រើនកម្រិត
- ផលិតឯកសារ និងសម្ភារៈឧបទេសសម្រាប់បង្រៀន
- ច្នៃប្រឌិតការបង្រៀនដើម្បីសិស្សទទួលបានចំណេះដឹង ចំណេះធ្វើ និងឥរិយាបថល្អ។

**គ- ចរិយាសម្បទា**

- ឲ្យតម្លៃ និងជឿជាក់ទៅលើទ្រឹស្តីគរុកោសល្យ
- យកចិត្តទុកដាក់អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្រថ្មីៗក្នុងការបង្រៀន។
- ឲ្យតម្លៃលើជំនាញវិជ្ជាជីវៈគ្រូបង្រៀន និងការអប់រំ ការច្នៃប្រឌិត និងការសិក្សាស្រាវជ្រាវ ដើម្បីបង្រៀន និងអប់រំសិស្សក្លាយជាពលរដ្ឋល្អក្នុងសង្គម។

## ៣- គោលគំនិតសំខាន់ៗ

- និន្នាការអប់រំពិភពលោក
- គោលនយោបាយ និងគោលដៅអប់រំជាតិ
- ច្បាប់ស្តីពីការអប់រំ
- ទ្រឹស្តីនានាស្តីពីការបង្រៀន និងរៀន
- យល់ដឹងវិធីសាស្ត្របង្រៀន វិធីសាស្ត្រជំរុញលើកទឹកចិត្តសិស្ស
- យល់ដឹងខ្លឹមសារនៃការបង្រៀន លំនាំនៃការបង្រៀន គោលការណ៍នៃការបង្រៀន
- យល់ដឹងទ្រឹស្តីនៃការបង្រៀន។

## ៤- របាយម៉ោងសិក្សា

របាយម៉ោងសិក្សា នៃមុខវិជ្ជាគរុកោសល្យ ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| **មុខវិជ្ជា** | **រយៈពេលសិក្សា** |
|---|---|
| គរុកោសល្យ | **៣ ក្រេឌីត ស្មើ ៤៥ ម៉ោងសិក្សា** |

## ៥- ការណែនាំអនុវត្ត

ដើម្បីអនុវត្តការបង្រៀនលើមុខវិជ្ជានេះ ឲ្យបានជោគជ័យគ្រូបង្រៀនគប្បី

- ឲ្យគរុនិស្សិតក្តាប់បានពីចំណុចគន្លឹះសំខាន់ៗនៃមេរៀនដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្រថ្មីៗក្នុងការបង្រៀន។ ជំរុញការសិក្សាតាមបែបសកម្មតាមរយៈការងារជាបុគ្គល ជាដៃគូ ជាក្រុម និងការស្រាវជ្រាវលើឯកសារជំនួយផ្សេងៗ។

- សម្របសម្រួលគរុនិស្សិតក្នុងការក្តាប់បាននូវខ្លឹមសារមេរៀនដោយធ្វើការវិភាគលើស្ថានភាព និងការពិភាក្សារកដំណោះស្រាយនៃបញ្ហាដើម្បីទទួលបានទាំងចំណេះជំនាញបំណិនប្រសប់និងឥរិយាបថល្អ ដែលសង្គមត្រូវការឲ្យស្របទៅតាមគោលដៅកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៦- ការវាយតម្លៃ

ការវាយតម្លៃ គឺជាចំណុចសំខាន់ ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាទទួលបានធៀបទៅនឹងវត្ថុបំណង នៃមេរៀនឬចំណុចអប្បរមានៃចំណេះអ្នកសិក្សាដែលគួរទទួលបានបន្ទាប់ពីបានបញ្ចប់ចំណុចនៃការសិក្សានីមួយៗ និងបញ្ចប់មុខវិជ្ជា។

- វិន័យ និងឥរិយាបថ (១៥ %)
- ការវាយតម្លៃជាដំណាក់ (៣០ %)
- សរសេររបាយការណ៍គម្រោង (៣០ %)
- ការប្រឡងបញ្ចប់មុខវិជ្ជា (២៥ %)

## ៧- តារាងកម្មវិធីសិក្សាលម្អិត

| ខ្លឹមសារ | លទ្ធផលសិក្សា | ម៉ោង |
|---|---|---|
| (៣ក្រេឌីត ស្មើនឹង ៤៥ ម៉ោង) | | |
| **មេរៀនទី១**<br>**បញ្ហាទូទៅនៃគរុកោសល្យ**<br>១.១- វត្ថុបំណងនៃគរុកោសល្យ<br>១.២- ធម្មជាតិពិតប្រាកដរបស់ការអប់រំ<br>១.៣- អំពើអប់រំដែលជះឥទ្ធិពលលើការអភិវឌ្ឍសង្គម<br>១.៤-ទំនាក់ទំនងរវាងការអប់រំនិងនយោបាយ<br>១.៥- កម្មវត្ថុរបស់គរុកោសល្យទូទៅ<br>១.៦- ចិត្តវិទ្យា និងគរុកោសល្យ<br>១.៧- តួនាទីរបស់គរុកោសល្យទូទៅ | **វិជ្ជាសម្បទា**<br>- គរុនិស្សិតពន្យល់បានពីនិយមន័យនៃគរុកោសល្យ<br>- បង្ហាញពីមុខងារនៃការអប់រំគរុកោសល្យព្រមទាំងតួនាទីរបស់គរុកោសល្យក្នុងការបង្ហាត់បង្រៀន។<br>- បង្ហាញទំនាក់ទំនងរវាងការអប់រំ និងនយោបាយ<br>**បំណិនសម្បទា**<br>- រៀបរាប់បានពីទំនាក់ទំនងរវាងការអប់រំនិងនយោបាយ<br>- ប្រាប់បានពីកម្មវត្ថុរបស់គរុកោសល្យ<br>**ចរិយាសម្បទា**<br>- ឲ្យតម្លៃនិងជឿជាក់លើទ្រឹស្តីគរុកោសល្យក្នុងការអប់រំ<br>- ទទួលស្គាល់ពីទំនាក់ទំនងរវាងចិត្តវិទ្យា និងគរុកោសល្យ | ៦ ម៉ |
| **មេរៀនទី២**<br>**វិធីបង្រៀន**<br>២.១- សញ្ញាណទូទៅ<br>២.២- ប្រព័ន្ធវិធីបង្រៀន<br>២.៣- វិធីបង្រៀនតាមប្រពៃណី<br>ក- វិធីឧទ្ទេស<br>ខ- វិធីប្រើប្រាស់សៀវភៅសិក្សា<br>គ- វិធីចោទឆ្លើយ | **វិជ្ជាសម្បទា**<br>- ពន្យល់ពីសញ្ញាណទូទៅរបស់វិធីបង្រៀនទាំង៨<br>- បកស្រាយពីវិធីបង្រៀនតាមបែបប្រពៃណីទាំងប្រាំបីបានត្រឹមត្រូវល្អ<br>**បំណិនសម្បទា**<br>- រកឃើញពីចំណុចខ្លាំង ចំណុចខ្សោយនៃវិធីបង្រៀនដោយផ្អែកលើមូលដ្ឋានជាក់លាក់ | ៦ ម៉ |

| | | |
|---|---|---|
| ឃ- វិធីអព្ភន្តរញាណ<br>ង- វិធីធ្វើពិសោធន៍<br>ច- វិធីហ្វឹកហ្វឺន<br>ឆ- វិធីសារឡើងវិញ<br>ជ- វិធីធ្វើកិច្ចការត្រួតពិនិត្យ វាយ-តម្លៃចំណេះដឹងចំណេះធ្វើនិងបំណិន ប្រសប់ | - ជ្រើសរើសនិងគួបផ្សំវិធីបង្រៀនដើម្បីយកទៅអនុវត្តក្នុងការបង្រៀន<br>**ចរិយាសម្បទា**<br>- អាចបត់បែនសកម្មភាពបង្រៀនតាមវិធីបង្រៀន និងខ្លឹមសារមេរៀន | |
| **មេរៀនទី៣**<br>**ការគ្រប់គ្រងថ្នាក់រៀន**<br>៣.១- និយមន័យនៃការគ្រប់គ្រងថ្នាក់រៀន<br>៣.២- គោលដៅនៃការគ្រប់គ្រងថ្នាក់រៀន<br>៣.៣- ការរៀបចំផែនការសម្រាប់ការគ្រប់គ្រងថ្នាក់រៀន<br>៣.៤- យុទ្ធសាស្ត្រ និងបច្ចេកទេសក្នុងការគ្រប់គ្រងថ្នាក់រៀន<br>៣.៥- ការឆ្លើយតបទៅនឹងអាកប្បកិរិ-យាមិនសមរម្យរបស់សិស្ស | **វិជ្ជាសម្បទា**<br>- កំណត់បានពីបញ្ញត្តិការគ្រប់គ្រងថ្នាក់រៀន<br>- ប្រាប់បានពីវិធីសាស្ត្រនានាក្នុងការគ្រប់គ្រងថ្នាក់រៀន<br>**បំណិនសម្បទា**<br>- បង្ហាញពីទស្សនៈឬគំនិតនិងវិធីផ្សេងៗការគ្រប់គ្រងថ្នាក់រៀន តាមរយៈការពិភាក្សាក្រុមពិភាក្សា<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃទៅលើសម្បទាក្នុងការគ្រប់គ្រងថ្នាក់រៀន និងចូលរួមដោយយក ចិត្តទុកដាក់បំផុត។ | ៤.៣០ម៉ |
| **មេរៀនទី៤**<br>**ពហុបញ្ញារបស់មនុស្ស**<br>៤.១- និយមនៃបញ្ញា<br>៤.២- សកម្មភាពអឌ្ឍគោលខួរក្បាល (ការគិត និងការរៀន)<br>៤.៣- ការបង្កើត និងពង្រីកបញ្ញា<br>៤.៤- បញ្ញាជាពហុតថភាព<br>៤.៥- ប្រភេទបញ្ញា<br>៤.៦- វិធីសាស្ត្របង្រៀនដោយប្រើពហុបញ្ញា<br>៤.៧- របៀបរៀនរបស់សិស្ស | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យនៃបញ្ញា<br>- រៀបរាប់បានពីតួនាទីរបស់អឌ្ឍខួរក្បាល និងប្រភេទនៃ<br>បញ្ញានីមួយៗ<br>**បំណិនសម្បទា**<br>- រកឃើញពីបញ្ញាផ្ទាល់ខ្លួន ប្រើប្រាស់ និងពង្រីកបញ្ញាបានយ៉ាងត្រឹមត្រូវ<br>- បង្ហាញបានពីតួនាទី និងសារៈសំខាន់របស់ខួក្បាល<br>- ប្រើប្រាស់បានពីវិធីបង្រៀនដោយប្រើពហុ បញ្ញា<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃលើខ្លឹមសារមេរៀន<br>- ចូលរួមលើកកម្ពស់សិស្សក្នុងការអភិវឌ្ឍបញ្ញា | ៤.៣០ម៉ |

| | | |
|---|---|---|
| **មេរៀនទី៥**<br>**ការលើកទឹកចិត្តក្នុងការរៀន និងបង្រៀន**<br>៥.១- និយមន័យ<br>៥.២- ទ្រឹស្តីផ្សេងៗពាក់ព័ន្ធការលើកទឹកចិត្ត<br>៥.៣- យុទ្ធសាស្ត្រ និងវិធីសាស្ត្រក្នុងការជម្រុញទឹកចិត្តសិស្ស<br>៥.៤- ការលើកទឹកចិត្តនៅក្នុងថ្នាក់រៀន | **ចំណេះសម្បទា**<br>- ណែនាំឲ្យស្គាល់ពីនិយមន័យវិធីសាស្ត្រលើកទឹកចិត្ត<br>- បង្ហាញច្បាស់លាស់ពីគំរូដោះស្រាយបញ្ហា ។<br>- ពណ៌នាពីកត្តាទាំងនោះយ៉ាងច្បាស់លាស់ ។<br>**បំណិនសម្បទា**<br>- បកស្រាយច្បាស់លាស់នូវខ្លឹមសារជំហានទាំងប្រាំ។<br>**ចរិយាសម្បទា**<br>- មានអំណត់អត់ធ្មត់ក្នុងការដោះស្រាយបញ្ហា ។ | ៤.៣០ម៉ |
| **មេរៀនទី៦**<br>**បំណិននៃការគិតលំដាប់ខ្ពស់**<br>៦.១- បំណិនគិតលំដាប់ខ្ពស់<br>៦.២- ការដោះស្រាយបញ្ហា<br>៦.៣- ការធ្វើការសម្រេចចិត្ត<br>៦.៤- បំណិននៃការគិតប្រកបដោយសុភវិនិច្ឆ័យ ( Critical Thinking Skill) | **ចំណេះសម្បទា**<br>- ប្រាប់ពីបំណិនការគិតលំដាប់ខ្ពស់<br>- ដឹងពីការដោះស្រាយបញ្ហា និងចេះធ្វើការសម្រេចចិត្ត<br>- បកស្រាយពីទស្សនៈផ្សេងគ្នានៃការគិតលំដាប់ខ្ពស់ និងទស្សនៈនៃការបង្រៀន<br>**បំណិនសម្បទា**<br>- បង្ហាញពីការគិតលំដាប់ខ្ពស់និងវិធីក្នុងការដោះស្រាយបញ្ហានិងទស្សនៈផ្សេងៗតាមរយៈការពិភាក្សាក្រុម<br>**ចរិយាសម្បទា**<br>- មានទំនួលខុសត្រូវខ្ពស់ក្នុងការដោះស្រាយបញ្ហា និងសម្រេចចិត្តដោយប្រើការគិតលំដាប់ខ្ពស់។ | ៦ម៉ |
| **មេរៀនទី៧**<br>**ខ្លឹមសារនៃការបង្រៀន**<br>៧.១- សញ្ញាណស្តីពីការបង្រៀន<br>៧.២- ចរិតប្រវត្តិសាស្ត្ររបស់ខ្លឹមសារនៃការបង្រៀន<br>៧.៣- គោលការណ៍ជាមូលដ្ឋានក្នុងការរៀបចំខ្លឹមសារនៃការបង្រៀន<br>៧.៤- ផែនការបង្រៀនកម្មវិធីសិក្សា សៀវភៅ និងឯកសារសិក្សា | **ចំណេះសម្បទា**<br>- រៀបរាប់ពីសញ្ញាណស្តីពីការបង្រៀន<br>- ពន្យល់ពីលក្ខណៈជាប្រវត្តិសាស្ត្ររបស់ខ្លឹមសារនៃការបង្រៀន<br>- ពន្យល់ពីផែនការបង្រៀន កម្មវិធីសិក្សា សៀវភៅ និងឯកសារសិក្សា<br>**បំណិនសម្បទា**<br>- បង្ហាញពីគោលការណ៍ជាមូលដ្ឋានសម្រាប់តាក់តែងខ្លឹមសារនៃការបង្រៀន<br>**ចរិយាសម្បទា**<br>- ឲ្យតម្លៃលើខ្លឹមសារនៃការបង្រៀនកាន់តែច្រើនឡើង | ៤.៣០ម៉ |

| | | |
|---|---|---|
| **មេរៀនទី៨**<br>**លំនាំនៃការបង្រៀន**<br>៨.១- សញ្ញាណទូទៅស្ដីពីលំនាំនៃការបង្រៀន<br>៨.២- សារជាតិរបស់លំនាំនៃការបង្រៀន<br>៨.៣- ភាពសមហេតុផលនៅក្នុងលំនាំនៃការបង្រៀន<br>៨.៤- កម្លាំងចលកររបស់លំនាំនៃការបង្រៀន<br>៨.៥- សន្និដ្ឋានគរុកោសល្យ | **វិជ្ជាសម្បទា**<br>- បកស្រាយពន្យល់ពីនិយមន័យសញ្ញាណទូទៅ និងភាពសមហេតុផល នៃលំនាំនៃការបង្រៀន<br>- សរសេររៀបរាប់ពីលំនាំនៃការបង្រៀនពីដំណាក់កាលរបស់លំនាំបង្រៀននិងកម្លាំងចលកររបស់លំនាំនៃការបង្រៀន<br>**បំណិនសម្បទា**<br>- យកខ្លឹមសារទាំងនោះទៅអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការបង្រៀន។<br>- បង្ហាញពីកម្លាំងចលកររបស់លំនាំនៃការបង្រៀន។<br>**ចរិយាសម្បទា**<br>- ផ្លាស់ប្ដូរសកម្មភាពបង្រៀនឲ្យស្របតាមលំនាំនៃការបង្រៀន | ៤.៣០ម៉ |
| **មេរៀនទី៩**<br>**គោលការណ៍នៃការបង្រៀន**<br>៩.១-សញ្ញាណទូទៅស្ដីពីគោលការណ៍នៃការបង្រៀន<br>៩.២- លក្ខណៈប្រវត្តិសាស្ត្ររបស់គោលការណ៍នៃការបង្រៀន<br>៩.៣- ប្រព័ន្ធគោលការណ៍នៃការបង្រៀន | **វិជ្ជាសម្បទា**<br>- ពន្យល់ពីនិយមន័យរបស់គោលការណ៍នៃការបង្រៀន<br>**បំណិនសម្បទា**<br>- រៀបរាប់ពីលក្ខណៈប្រវត្តិសាស្ត្ររបស់គោលការណ៍នៃការបង្រៀន<br>- ពណ៌នាពីប្រព័ន្ធគោលការណ៍នៃការបង្រៀន<br>**ចរិយាសម្បទា**<br>- បង្រៀនសិស្សបានសមស្របតាមគោលការណ៍នៃការបង្រៀន<br>- ឲ្យតម្លៃជឿជាក់លើគោលការណ៍បង្រៀន | ៤.៣០ម៉ |

## ៨- ឯកសារយោង


- ចាន់ វឌ្ឍសុផា (២០០៧). *ចិត្តវិទ្យាអប់រំភាគ១* .ភ្នំពេញ
- ចាន់ វឌ្ឍសុផា (២០១២). *ចិត្តវិទ្យាអប់រំភាគ២*.ភ្នំពេញ
- នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រិតការ(២០០៤).*ឯកសារគរុកោសល្យសម្រាប់ បំប៉នសមត្ថភាពគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ*.ភ្នំពេញៈ ក្រសួងអប់រំយុវជន និងកីឡា
- នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រិតការ(២០០២).*គរុកោសល្យ*.ភ្នំពេញៈក្រសួងអប់រំយុវជ និងកីឡា
- វិទ្យាស្ថានជាតិអប់រំ.(២០២១). *ក្របខណ្ឌកម្មវិធីបណ្ដុះបណ្ដាល គ្រូបង្រៀនកម្រិតឧត្ដម(បរិញ្ញា+២)*. ភ្នំពេញៈ វិទ្យាស្ថានជាតិអប់រំ.

# ស្រាវជ្រាវអប់រំ

## ១- សេចក្តីផ្តើម

ការស្រាវជ្រាវអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងកំពុងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅលើពិភពលោក ពីព្រោះប្រភពនៃចំណេះដឹងពេញលេញ និងទំនួលខុសត្រូវក្នុងភាពជោគជ័យនៃការធ្វើផែនការអប់រំ។ ស្របពេលជាមួយការអភិវឌ្ឍជំនាញវិជ្ជាជីវៈនៃការស្រាវជ្រាវឥតឈប់ឈរក្នុងបរិបទឌីជីថលគឺ ជាចំណុចគន្លឹះនៅក្នុងចំណោមកត្តាជាច្រើនដើម្បីអភិវឌ្ឍចំណេះដឹង និងការអនុវត្តតាមបែបវិទ្យាសាស្ត្រ។ ការស្រាវជ្រាវ គឺជាការបើកឱកាសក្នុងការសិក្សាស្វែងយល់អំពីទស្សនៈ ការអនុវត្ត ប្រពៃណី ទំនៀមទម្លាប់ តម្លៃ និងបាតុភូតធម្មជាតិផ្សេងៗក្នុងគោលដៅបង្ហាញសង្គតិភាព នវានុវត្តន៍ និងការបង្កើតថ្មី។ លោក Creswell (2014) បានលើកឡើងថា ការស្រាវជ្រាវគឺជាការបើកចំហរពិភពនៃការអនុវត្ត ការគិត បាតុភូត ឬដំណើរធម្មជាតិរបស់សភាវៈរស់ទាំង៤ប្រភេទគឺ (១) វិជ្ជមាន (២) ស្ថាបនា (៣) អនុវត្ត និង (៤) ចូលរួម។ បន្ទាប់មកការសិក្សាបែបស្ថាបនា និងចូលរួម ត្រូវបានគេស្គាល់ថា ការសិក្សាគុណវិស័យដោយផ្តោតលើការវិភាគស៊ីជម្រៅ រិះរកហេតុ និងផល។ ទន្ទឹមនឹងនេះការសិក្សាបែបវិជ្ជមានមានន័យថាត្រូវបានហៅថា ការសិក្សាបរិមាណវិស័យ និងបែបអនុវត្តមានន័យថាការសិក្សាចម្រុះ។

ទស្សនវិជ្ជាដែលជាមគ្គុទេសក៍ក្នុងការអភិវឌ្ឍឯកសារនេះមានពីរចំណុចដូចខាងក្រោម ៖

**ចំណុចទី១** របៀបស្រាវជ្រាវដែលពាក់ព័ន្ធទៅនឹងដំណើរការនៃសកម្មភាពដែលប្រទាក់ក្រឡាគ្នាជា ជាងការអនុវត្ត ភាពឯកោនិងគ្មានទំនាក់ទំនង រួមទាំងគំនិតនៃការយល់ដឹងអំពីលំហូរសកម្មភាពជា ចំណុចចម្បងនៃការសិក្សាស្រាវជ្រាវ។

**ចំណុចទី២** អ្នកស្រាវជ្រាវអប់រំសព្វថ្ងៃត្រូវការប្រអប់ឧបករណ៍ដ៏ធំមួយនៃវិធីសាស្ត្រស្រាវជ្រាវដើម្បីសិក្សាពីបញ្ហាអប់រំដែលស្មុគស្មាញនៅក្នុងសង្គមរបស់យើងនាពេលបច្ចុប្បន្ន។

ឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩ - ២០២៣ ដោយឈរលើគោលនយោបាយចំនួន២គឺ (១) ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន ដើម្បីលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង (២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវគោលនយោបាយទាំងពីរខាងលើ ការបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តមបរិញ្ញាបត្រ+២ លើមុខវិជ្ជាស្រាវជ្រាវអប់រំ គឺជាកត្តាដែលមិនអាចខ្វះបានស្របពេលដែលក្រសួង បាននឹងកំពុងយកចិត្តទុកដាក់ទៅលើការធ្វើកំណែទម្រង់ វិស័យអប់រំ ឆ្ពោះទៅរកគុណភាព និងប្រសិទ្ធភាព ដើម្បីលើកស្ទួយប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅក្នុងឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

## ២- គោលបំណង

- បណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តមឱ្យក្លាយជាអ្នកស្រាវជ្រាវអប់រំប្រកបដោយគុណវុឌ្ឍិ
- លើកកម្ពស់សមត្ថភាពជំនាញវិជ្ជាជីវៈគ្រូបង្រៀននៅក្នុងវិស័យអប់រំឱ្យមានភាពប្រសើរឡើង។

## ៣- វត្ថុបំណង

### ក- វិជ្ជាសម្បទា

- កំណត់ពីបទបញ្ញត្តិដែលគេហៅថាទូទៅ-ជាក់លាក់ និង ជាក់លាក់-ទូទៅ, អំពីលំហូរបញ្ហា, ដំណើរការ

និងដំណោះស្រាយ, ទំនាក់ទំនងរបស់ ការអត្ថាធិប្បាយលើទិន្នន័យ, ការសរសេរសង្ខេប, ឆ្លុះបញ្ចាំង និង ការបង្កើតអត្ថបទស្រាវជ្រាវតាមលក្ខណៈបច្ចេកទេសស្របតាមលក្ខខណ្ឌវិនិច្ឆ័យអត្ថបទស្រាវជ្រាវ

- បកស្រាយអំពីប្រភេទអត្ថបទស្រាវជ្រាវដូចជា អត្ថបទស្រាវជ្រាវដើម អត្ថបទស្រាវជ្រាវរំឮក និងអត្ថបទស្រាវជ្រាវវិភាគ

- បកស្រាយអំពីមូលដ្ឋានគ្រឹះនៃការសិក្សាបែបគុណវិស័យ និងវិធីសាស្ត្របែបគុណវិស័យដូចជា ការស្រាវជ្រាវបែបរឿងព្រេង ការស្រាវជ្រាវជាតិពន្ធុសាស្ត្រ និងការស្រាវជ្រាវតាមករណីសិក្សា

- បកស្រាយអំពីរបៀបប្រមូលទិន្នន័យគុណវិស័យដូចជា ការសម្ភាស ការពិភាក្សាក្រុម និងការអង្កេត

- បកស្រាយអំពីការស្រាវជ្រាវបរិមាណវិស័យ រួមមានការវាស់ស្ទង់ និងការពិសោធន៍ បានត្រឹមត្រូវដែលមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់

- បកស្រាយអំពីការស្រាវជ្រាវចម្រុះ រួមមានការរចនាបែបបង្រួម ការរចនាបែបពន្យល់ និងការរចនាបែបរុករកបានត្រឹមត្រូវ

- បកស្រាយអំពីការវិភាគទិន្នន័យតាមកម្មវិធី SPSS។

**ខ- បំណិនសម្បទា**

- រៀបចំផែនទីគំនិតតាមលំដាប់លំហូរនៃទូទៅ-ជាក់លាក់ និង ជាក់លាក់-ទូទៅ និងលំហូរបញ្ហាដើម្បីធ្វើសេចក្ដីព្រាងវិចារណនិពន្ធន៍បានត្រឹមត្រូវតាមប្រធានបទដែលបានកំណត់

- ចងក្រងផ្នែកនៃអត្ថបទទៅជាអត្ថបទទាំងមូលតាមរយៈការសង្ខេប សំយោគ និងដកស្រង់សម្ដី ជាមួយការផ្ដល់ឯកសារយោងបានត្រឹមត្រូវ

- កំណត់លក្ខណៈដូច និងខុសគ្នារបស់អត្ថបទស្រាវជ្រាវដើម, អត្ថបទស្រាវជ្រាវរម្លឹក និងអត្ថបទស្រាវជ្រាវវិភាគ, តាមរយៈការសំយោគ និងធ្វើសេក្ដីសន្និដ្ឋានបានត្រឹមត្រូវ

- សរសេរអត្ថបទស្រាវជ្រាវខ្លីៗ អំពីការសិក្សាតាមបែបគុណវិស័យតាមរយៈការធ្វើការងារក្រុម ដោយជ្រើសរើសប្រធានបទជាក់លាក់

- សរសេរអត្ថបទស្រាវជ្រាវខ្លីៗ អំពីការសិក្សាតាមបែបបរិមាណវិស័យតាមរយៈការធ្វើការងាក្រុម ដោយជ្រើសរើសប្រធានបទជាក់លាក់

- សរសេរអត្ថបទស្រាវជ្រាវខ្លីៗ អំពីការសិក្សាតាមបែបចម្រុះតាមរយៈការធ្វើការងារក្រុមដោយជ្រើសរើសប្រធានបទជាក់លាក់

- បង្កើតកម្រងសំណួរដើម្បីប្រមូលទិន្នន័យឈានដល់ការវិភាគ

- ប្រមូលទិន្នន័យតាមបែបគុណវិស័យ និងបរិមាណវិស័យ

- បញ្ចូលទិន្នន័យទាំងបរិមាណវិស័យ និងគុណវិស័យ

- វិភាគទិន្នន័យតាមបែបគុណវិស័យ បរិមាណវិស័យ និងតាមកម្មវិធីកុំព្យូទ័រ

- បំណកស្រាយលទ្ធផលស្រាវជ្រាវឱ្យបានត្រឹមត្រូវ។

**គ- ចរិយាសម្បទា**

- មានឆន្ទៈខ្ពស់ក្នុងការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈ សំដៅលើកម្ពស់ការសិក្សាពេញមួយជីវិត

- បណ្ដុះទម្លាប់អាន និងសរសេរអត្ថបទស្រាវជ្រាវដើម្បីបង្កើនចំណេះដឹង រួចបង្កើតសំណួរគន្លឹះតាមរយៈការសិក្សាដោយខ្លួនឯង និងមានភាពម្ចាស់ការលើការងារស្រាវជ្រាវ

- គោរពក្រមសីលធម៌វិជ្ជាជីវៈជាអ្នករសេរអត្ថបទស្រាវជ្រាវ និងមានឆន្ទៈក្នុងការចែករំលែក ចំណេះដឹងដល់និស្សិត-បញ្ញាវន្តតាមស្ថានភាពជាក់ស្ដែង និងកម្រិតនៃការយល់របស់ពួកគេ

- បណ្ដុះស្មារតីឱ្យមានការវិភាគបែបស៊ីជម្រៅ មានហេតុ និងផលច្បាស់លាស់

- មានឆន្ទៈខ្ពស់ក្នុងការសិក្សាទ្រឹស្ដី បទបញ្ញត្តិ និងគោលការណ៍ថ្មីៗដែលជាតម្រូវការជាក់ស្ដែង សម្រាប់អភិវឌ្ឍសមត្ថភាព ដែលជាគម្រូល្អដល់និស្សិត-បញ្ញាវន្តគ្រប់ជំនាន់។

## ៣- គោលគំនិតសំខាន់ៗ

ការបណ្ដុះបណ្ដាលមុខវិជ្ជាវិធីសាស្ត្រស្រាវជ្រាវអប់រំនៅវិទ្យាស្ថានជាតិអប់រំ(NIE) សម្រាប់ថ្នាក់ (បរិញ្ញាបត្រ+២) ឱ្យយល់ដឹងពីមូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រាំមួយចំណុចរួមមាន ៖

- វិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យ
- វិធីសាស្ត្រស្រាវជ្រាវគុណវិស័យ
- វិធីសាស្ត្រស្រាវជ្រាវចម្រុះ
- វិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិ
- ការសរសេរ និងបោះពុម្ពអត្ថបទស្រាវជ្រាវ
- ការបង្កើតគម្រោងស្រាវជ្រាវ និងស្នើសុំមូលនិធិស្រាវជ្រាវ។

## ៤- របាយម៉ោងសិក្សា

របាយម៉ោងសិក្សានៃមុខវិជ្ជា **ស្រាវជ្រាវអប់រំ** ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| **មុខវិជ្ជា** | **រយៈពេលសិក្សា** |
|---|---|
| **ស្រាវជ្រាវអប់រំ** | **៣ ក្រេឌីត ស្មើ ៤៥ ម៉ោងសិក្សា** |

## ៥- ការណែនាំអនុវត្ត

- បណ្ដុះគំនិត បញ្ញា និងស្មារតីផ្នែកស្រាវជ្រាវអប់រំប្រកបដោយគុណធម៌
- ជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវដើម្បីបង្កលក្ខណៈគ្រប់លក្ខខណ្ឌឱ្យមានសកម្មភាពហ្វឹកហាត់
- លើកកម្ពស់ការស្រាវជ្រាវប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ
- ណែនាំឱ្យសង្កេត ពិចារណា និងពិភាក្សាទៅលើប្រធានបទដែលគេធ្លាប់បានសិក្សាកន្លងមក
- ប្រើកម្រងសំណួរបិទ កម្រងសំណួរបើក កម្រងសំណួររូបភាព និងកម្រងសំណួរចម្រុះ
- របៀបវិភាគ និងសំយោគសម្រាប់បំបែកចំណេះដឹងដែលស្មុគស្មាញជាបំណែកតូចៗ

## ៦- ការវាយតម្លៃ

នីតិវិធីក្នុងការវាយតម្លៃត្រូវរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អបន្ថែមដើម្បីឈានទៅដល់ការកាត់បន្ថយភាពអសកម្ម ដូចជា ៖

- គម្រោងស្រាវជ្រាវនេះបានឆ្លុះបញ្ចាំងច្បាស់លាស់ពីបញ្ហាក្នុងការអនុវត្តដែលត្រូវដោះស្រាយ
- អ្នកស្រាវជ្រាវប្រមូលទិន្នន័យគ្រប់ជ្រុងជ្រោយដើម្បីដោះស្រាយបញ្ហាដែលចង់ដឹង
- អ្នកស្រាវជ្រាវមានកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ
- អ្នកស្រាវជ្រាវត្រូវគោរពគ្នាទៅវិញទៅមកប្រកបដោយគុណធម៌

- រៀបចំផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហាឱ្យមានភាពស៊ីសង្វាក់គ្នាទៅវិញទៅមក

- មានភស្តុតាងបញ្ជាក់ពីផែនការសកម្មភាពដែលបានបង្កើតផ្អែកលើការឆ្លុះបញ្ចាំងរបស់អ្នកស្រាវជ្រាវសម្រាប់យកទៅអនុវត្តវិជ្ជាជីវៈជាក់ស្តែង

- ការស្រាវជ្រាវមានលក្ខណៈទូលំទូលាយ ជំរុញដល់គុណតម្លៃនៃជីវិតដល់អ្នកចូលរួមតាមរយៈការផ្តល់សិទ្ធិអំណាច ការផ្លាស់ប្តូរ និងការអភិវឌ្ឍបំណិនសតវត្សទី២១

- ការស្រាវជ្រាវពិតជាមានគុណតម្លៃ និងជំរុញឱ្យមានការផ្លាស់ប្តូរប្រកបដោយនវានុវត្តន៍

- របាយការណ៍ និងការបង្ហាញលទ្ធផលស្រាវជ្រាវបានដល់ក្រុមគោលដៅសម្រាប់ការប្រើប្រាស់។

## ៧- តារាងកម្មវិធីសិក្សាលម្អិត

| ខ្លឹមសារគោល | លទ្ធផលសិក្សា | ម៉ោង |
|---|---|---|
| **១៥ម៉ោង x ៣ក្រេឌីត = ៤៥ម៉ោង** | | |
| **មេរៀនទី១  វិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យ** | | ៩.00 ម៉ |
| ១.១  មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវបែបបរិមាណវិស័យ<br>១.២  វិធីសាស្ត្រក្នុងចងក្រង និងកែសម្រួលកម្រងសំណួរ<br>១.៣  ការសិក្សាបែបវាស់ស្ទង់ និងបញ្ញត្តិសំខាន់ៗ<br>១.៤  ការសិក្សាបែបពិសោធន៍ និងបញ្ញត្តិសំខាន់ៗ<br>១.៥ ការវិភាគទិន្នន័យដោយប្រើកម្មវិធី SPSS | **វិជ្ជាសម្បទា**<br>• រៀបរាប់ពីគោលការណ៍ និងបញ្ញត្តិសំខាន់ៗនៃការស្រាវជ្រាវបរិមាណវិស័យបានត្រឹមត្រូវតាមលក្ខណៈស្រាវជ្រាវ<br>• ពណ៌នាពីរបៀបចងក្រង និងកែសម្រួលកម្រងសំណួរដោយមានបញ្ជាក់ឯកសារយោងត្រឹមត្រូវ<br>• រៀបរាប់ពីរបៀបក្នុងការប្រមូលទិន្នន័យ តាមបែបបរិមាណវិស័យ<br>• ប្រាប់ពីគោលការណ៍ និងបញ្ញត្តិសំខាន់ៗ របស់ការសិក្សាបែបវាស់ស្ទង់ និងបែបពិសោធន៍បានត្រឹមត្រូវ<br>• បង្ហាញកម្មវិធី SPSS ក្នុងការវិភាគទិន្នន័យ<br>**បំណិនសម្បទា**<br>• សរសេរវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យបានត្រឹមត្រូវតាមលក្ខណៈស្រាវជ្រាវ<br>• ចងក្រង និងកែសម្រួលកម្រងសំណួរដោយមានបញ្ជាក់ឯកសារយោងត្រឹមត្រូវ | |

| | | |
|---|---|---|
| | • ប្រមូលទិន្នន័យតាមបរិមាណវិស័យតាមរយៈកម្រងសំណួរបានត្រឹមត្រូវ<br>• បកស្រាយគោលការណ៍ និងបញ្ញត្តិសំខាន់ៗ របស់ការសិក្សា បែបវាស់ស្ទង់ និងបែបពិសោធន៍បានត្រឹមត្រូវ<br>• ប្រើប្រាសកម្មវិធី SPSS ក្នុងការវិភាគទិន្នន័យ<br>**ចរិយាសម្បទា**<br>• មានទំនួលខុសត្រូវ និងទំនុកចិត្តក្នុងការសរសេរវិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យ និងការប្រើប្រាស់កម្មវិធី SPSS ក្នុងការវិភាគទិន្នន័យ<br>• មានទំនួលខុសត្រូវ និងទំនុកចិត្តក្នុងការបង្រៀនពីគោលការណ៍ និងបញ្ញត្តិនៃការស្រាវជ្រាវបែបវាស់ស្ទង់ និងការស្រាវជ្រាវបែបពិសោធន៍ | |
| **មេរៀនទី២ វិធីសាស្ត្រស្រាវជ្រាវគុណវិស័យ** | | ៩.០០ម៉ |
| ២.១ មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវគុណវិស័យ<br>២.២ វិធីសាស្ត្រក្នុងការសម្ភាសន៍ ការសង្កេត និង ការពិភាក្សាក្រុមសម្រាប់ការស្រាវជ្រាវគុណវិស័យ<br>២.៣ ការសរសេរអត្ថបទស្រាវជ្រាវបែបរឿងព្រេង និងបញ្ញត្តិសំខាន់ៗ<br>២.៤ ការសរសេរអត្ថបទស្រាវជ្រាវបែបករណីសិក្សា និងបញ្ញត្តិសំខាន់ៗ<br>២.៥- ការសរសេរទិន្នន័យបែបគុណវិស័យ ការចាប់កូដ ការរៀបចំចំណងជើង និងចំណងជើងរងនៃលទ្ធផលសិក្សាគុណវិស័យ<br>២.៦ ការសរសេរការពិភាក្សាលទ្ធផលសិក្សា និងការឆ្លើយសំណួរស្រាវជ្រាវ | **វិជ្ជាសម្បទា**<br>• រៀបរាប់ពីគោលការណ៍ និងបញ្ញត្តិសំខាន់ៗនៃការស្រាវជ្រាវបែបគុណវិស័យបានត្រឹមត្រូវតាមលក្ខណៈស្រាវជ្រាវ<br>• ពណ៌នាពីរបៀបក្នុងការសម្ភាសន៍ ការសង្កេត និងការពិភាក្សាក្រុមដើម្បីប្រមូលទិន្នន័យស្រាវជ្រាវគុណវិស័យ<br>• ប្រាប់ពីរបៀបសរសេរកូដ<br>• រៀបចំចំណងជើង និងចំណងជើងរងនៃលទ្ធផលសិក្សាបែបគុណវិស័យ<br>**បំណិនសម្បទា**<br>• សរសេរវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យបានត្រឹមត្រូវតាមលក្ខណៈស្រាវជ្រាវ | |

| | | |
|---|---|---|
| | • ប្រមូលទិន្នន័យស្រាវជ្រាវបែបគុណវិស័យរួមមានការសម្ភាសន៍ ការសង្កេត និងការពិភាក្សាក្រុមបានត្រឹមត្រូវតាម វិជ្ជាជីវៈអ្នកស្រាវជ្រាវ។<br>• សរសេរកូដ  ការរៀបចំចំណងជើង និងចំណងជើងរងនៃលទ្ធផលសិក្សាគុណវិស័យបានត្រឹមត្រូវតាមបែបសិក្សាធិការ<br>**ចរិយាសម្បទា**<br>• មានទំនួលខុសត្រូវ និងទំនុកចិត្តក្នុងការសរសេរវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យដោយមានឯកសារយោងត្រឹមត្រូវ និងមានភាពប៉ិនប្រសប់ក្នុងការប្រមូលទិន្នន័យស្រាវជ្រាវដោយគោរពតាមសីលធម៌វិជ្ជាជីវៈរបស់អ្នកស្រាវជ្រាវ | |
| **មេរៀនទី៣ វិធីសាស្ត្រស្រាវជ្រាវចម្រុះ** | | ៧.៣០ម៉ |
| ៦.១ មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវចម្រុះ និងបញ្ញត្តិសំខាន់ៗ<br>៦.២ វិធីសាស្ត្រ និងជំហានក្នុងការស្រាវជ្រាវចម្រុះ<br>៦.៣ ការបញ្ចូល និងវិភាគទិន្នន័យទាំងគុណវិស័យ និងបរិមាណវិស័យ<br>៦.៤ ការបកស្រាយលទ្ធផលស្រាវជ្រាវ | **វិជ្ជាសម្បទា**<br>• រៀបរាប់ពីគោលការណ៍ និងបញ្ញត្តិសំខាន់ៗនៃការស្រាវជ្រាវបែបចម្រុះបានត្រឹមត្រូវតាមលក្ខណៈស្រាវជ្រាវ<br>• ពណ៌នាពីរបៀបបញ្ចូល និងវិភាគទិន្នន័យបែបចម្រុះ ( ទាំងគុណវិស័យ និងបរិមាណវិស័យ )បានត្រឹមត្រូវ<br>• ប្រាប់ពីរបៀបបកស្រាយទិន្នន័យទាំងគុណវិស័យ និងបរិមាណវិស័យ<br>**បំណិនសម្បទា**<br>• សង្ខេបគោលការណ៍ និងបញ្ញត្តិសំខាន់ៗនៃការស្រាវជ្រាវចម្រុះបានត្រឹមត្រូវតាមលក្ខណៈស្រាវជ្រាវ<br>• ពន្យល់ពីរបៀបបញ្ចូល និងវិភាគទិន្នន័យបែបចម្រុះ ( ទាំងបែបគុណវិស័យនិងបរិមាណវិស័យ) បានត្រឹមត្រូវ | |

| | | |
|---|---|---|
| | • បកណាកស្រាយទិន្នន័យទាំងគុណវិស័យ និងបរិមាណវិស័យ<br>**ចរិយាសម្បទា**<br>• មានទំនួលខុសត្រូវ និងទំនុកចិត្តក្នុងការពន្យល់បកស្រាយបញ្ញត្តិ និងមានភាពប៉ិនប្រសព្វក្នុងមារសង្ខេបខ្លឹមសារពីរបៀបបកស្រាយទិន្នន័យទាំងគុណវិស័យ និងបរិមាណវិស័យ | |
| **មេរៀនទី៤ វិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិ** | | **៧.៣០ម៉** |
| ៤.១ ខ្លឹមសារគោលនៃវិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិក្នុងវិស័យអប់រំ<br>៤.២ ការរចនា និងដំណើរការនៃការស្រាវជ្រាវប្រតិបត្តិ<br>៤.៣ ប្រៀបធៀបរបៀបស្រាវជ្រាវប្រតិបត្តិ និងរបៀបស្រាវជ្រាវដទៃទៀតក្នុងវិស័យអប់រំប្រតិបត្តិ | **វិជ្ជាសម្បទា**<br>• កំណត់និយមន័យនៃវិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិ<br>• កំណត់អំពីរបៀបប្រើប្រាស់វិធីស្រាវជ្រាវប្រតិបត្តិ<br>• ទទួលបានចំណេះដឹងអំពីការរចនាវិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិ<br>• ទទួលបានចំណេះដឹងអំពីដំណើរការនៃវិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិ<br>• ទទួលបានចំណេះដឹងអំពីដំហាននៅក្នុងដំណើរការនៃការស្រាវជ្រាវប្រតិបត្តិ<br>• ទទួលបានចំណេះដឹងអំពីការយកចិត្តទុកដាក់ និងពង្រឹងស្ពេរភាពនៅក្នុងសហគមន៍<br>• កំណត់បាននូវភាពខ្វះខាតនៃចំណេះដឹងបច្ចេកទេស និងជំនាញស្រាវជ្រាវ<br>• កំណត់បាននូវបញ្ហាប្រឈមចំពោះការស្រាវជ្រាវក្នុងបរិបទជាក់ស្តែងនៃវិជ្ជាជីវៈគ្រូបង្រៀន<br>• ប្រៀបធៀបរបៀបស្រាវជ្រាវប្រតិបត្តិ និងរបៀបស្រាវជ្រាវទូទៅ<br>**បំណិនសម្បទា** | |

| | | |
|---|---|---|
| | • អនុវត្តការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិបានត្រឹមត្រូវ<br>• អនុវត្តការរចនាវិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិ<br>• អនុវត្តដំណើរការនៃវិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិ<br>• អនុវត្តប្រាំបីជំហាននៅក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិ<br>• អនុវត្តការគោរពក្រមសីលធម៌នៅក្នុងវិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិ<br>• លើកម្ពស់ការយកចិត្តទុកដាក់ និងការពង្រឹងស្មេរភាពនៅក្នុងសហគមន៍<br>• អភិវឌ្ឍចំណេះដឹងបច្ចេកទេស និងជំនាញក្នុងការស្រាវជ្រាវ<br>• ព្យាយាមដោះស្រាយបញ្ហាប្រឈមនៅពេលជួបប្រទះនៅក្នុងការអនុវត្តការស្រាវជ្រាវក្នុងបរិបទជាក់ស្តែងនៃវិជ្ជាជីវៈគ្រូបង្រៀន<br>• អនុវត្តការប្រៀបធៀបរបៀបស្រាវជ្រាវប្រតិបត្តិ និងរបៀបស្រាវជ្រាវទូទៅ<br>**ចរិយាសម្បទា**<br>• មានទំនួលខុសត្រូវ និងទំនុកចិត្តក្នុងការអនុវត្តវិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិបានត្រឹមត្រូវ | |
| **មេរៀនទី៥ ការសរសេរ និងការបោះពុម្ពអត្ថបទស្រាវជ្រាវ** | | ៦.០០ម៉ |
| ៥.១ គោលគំនិត និងតម្រូវការជាមូលដ្ឋាននៃការសរសេរអត្ថបទស្រាវជ្រាវ<br>៥.២ ដំណើរការនៃការបោះពុម្ពអត្ថបទស្រាវជ្រាវ | **វិជ្ជាសម្បទា**<br>• កំណត់គោលគំនិត និងតម្រូវការជាមូលដ្ឋាននៃការសរសេរអត្ថបទស្រាវជ្រាវ<br>• កំណត់ដំណើរការនៃការបោះពុម្ពអត្ថបទស្រាវជ្រាវ<br>**បំណិនសម្បទា** | |

| | | |
|---|---|---|
| | • ឈ្វេងយល់ពីគោលគំនិត និងតម្រូវការជាមូលដ្ឋាននៃអត្ថបទស្រាវជ្រាវ<br>• អនុវត្តដំណើរការនៃការបោះពុម្ពអត្ថបទស្រាវជ្រាវ<br>**ចរិយាសម្បទា**<br>• មានទំនួលខុសត្រូវ និងទំនុកចិត្តក្នុងការសរសេរ និងការបោះពុម្ពអត្ថបទស្រាវជ្រាវ | |
| **មេរៀនទី៦ ការបង្កើតគម្រោងស្រាវជ្រាវ និងស្នើសុំមូលនិធិស្រាវជ្រាវ** | | ៦.00ម៉ |
| ៦.១ បរិបទនៃការបង្កើតគម្រោងស្នើសុំមូលនិធិស្រាវជ្រាវ<br>៦.២ រចនាសម្ព័ន្ធ និងធាតុនៃសំណើមូលនិធិស្រាវជ្រាវ | **វិជ្ជាសម្បទា**<br>• ទទួលបានចំណេះដឹងអំពីការបង្កើតគម្រោងស្នើសុំមូលនិធិស្រាវជ្រាវ<br>• កំណត់បាននូវរចនាសម្ព័ន្ធ និងធាតុនៃសំណើមូលនិធិស្រាវជ្រាវ<br>**បំណិនសម្បទា**<br>• អនុវត្តសកម្មភាពបង្កើតគម្រោងស្នើសុំមូលនិធិស្រាវជ្រាវ<br>• លើកកម្ពស់រចនាសម្ព័ន្ធស្រាវជ្រាវ<br>• វិភាគធាតុនៃសំណើមូលនិធិស្រាវជ្រាវ<br>**ចរិយាសម្បទា**<br>មានទំនួលខុសត្រូវ និងទំនុកចិត្តក្នុងការអនុវត្តគម្រោងស្រាវជ្រាវ និងស្នើសុំមូលនិធិស្រាវជ្រាវបានត្រឹមត្រូវ | |

## ៨- ឯកសារយោង

### ក- ភាសាខ្មែរ


- សម្តេចសង្ឃ ជួន ណាត(១៩៦៧), វចនានុក្រមខ្មែរ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ភ្នំពេញ
- អយក(២០២១), ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+២), ភ្នំពេញ
- វិទ្យាស្ថានជាតិអប់រំ, (២០២១a), ការស្រាវជ្រាវបែបបរិមាណវិស័យ, ភ្នំពេញ
- វិទ្យាស្ថានជាតិអប់រំ, (២០១៣b), វិទ្យាសាស្ត្រស្រាវជ្រាវអប់រំ, ភ្នំពេញ


### ខ- ភាសាអង់គ្លេស


- Bennett, B. (2012). *Logically fallacious*. Sudbury, MA.
- Creswell, J. W. (2012). *Educational research: Planning, conducting, and evaluating quantitative and qualitative research.* (K. Mason Ed.). Boston: Boylston.

- Creswell, J. W. (2014). *Research design: Qualitative, quantitative, mixed methods approaches.* United States of America: SAGE.
- Creswell, J. W., & Clark, V. L. P. (2018). *Designing and conducting mixed methods research* (Third ed.). London: SAGE.
- Evans, D., Gruba, P., & Zobel, J. (2014). *How to write a better thesis.* (Third ed.). New York, NY: Springer.
- Fraenkel, J. R., Wallen, N. E., & Hyun, H. H. (2012). *How to design and evaluate research in education.* (Eighth ed.). New York, NY: McGrawHill.
- George A. Morgan, Nancy L. Leech, Gene W. Gleckner, & Barrett, K. C. (2011). *IBM SPSS for introductory statistics: Use and interpretation.* New York, NY: Routledge.
- Holm, C. (2015). *The 25 cognitive biases*. USA.
- Hopkins, D. (2008). *A teacher's guide to classroom research* (Fourth ed.). New York, NY: Open Univerisity Press.
- Lane, R. (2020). *Logic & analytical thinking*. USA.
- Mills, G. E., & Gay, L. R. (2016). *Educational research: Competencies for analysis and applications.* (Eleventh ed.). England: Pearson.
- Nunan, D. (1992). *Research methods in language teaching.* USA: Cambridge University Press.
- Swales, J. M., & Feak, C. B. (2012). *Academic Writing for Graduate Students* (Third ed.): Michigan ELT.

# បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន

## ១- សេចក្តីផ្តើម

បច្ចេកវិទ្យាថ្មីកំពុងផ្លាស់ប្តូរការអប់រំនៅលើពិភពលោក។ ដូច្នេះស្ថាប័នគរុកោសល្យទាំងអស់ត្រូវផ្លាស់ប្តូរវិធីសាស្រ្តបង្រៀននិងរចនាសម្ព័ន្ធនៃការបណ្តុះបណ្តាល ដោយផ្អែកលើបដិវត្តនៃបច្ចេកវិទ្យាថ្មី។ ដើម្បីសម្របទៅតាមការផ្លាស់ប្តូរនៃពិភពលោកក្នុងការទ្រទ្រង់ការបង្រៀន និងរៀនពីចម្ងាយ វិទ្យាស្ថានជាតិអប់រំបាននិងកំពុងបង្កើតកម្មវិធីសិក្សាថ្មីដើម្បីបណ្តុះបណ្តាលគរុនិស្សិតថ្មីឱ្យក្លាយជាគ្រូសតវត្សរ៍ទី២១ ដែលត្រូវតែដឹងពីរបៀបនៃការផ្ទេរចំណេះដឹងរបស់ពួកគេទៅដល់សិស្សរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។

កម្មវិធីសិក្សាសម្រាប់កុំព្យូទ័រទូទៅ ត្រូវបានបង្កើតឡើងដោយគ្រូឧទ្ទេសផ្នែកបច្ចេកវិទ្យាព័ត៌មានរបស់វិទ្យាស្ថានជាតិអប់រំដោយអនុវត្តតាមគរុកោសល្យក្នុងតំបន់ដូចជាប្រទេសថៃ សិង្ហបុរី វៀតណាម និងម៉ាឡេស៊ីនិងតាមគោលការណ៍និងទ្រឹស្តីនៃបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងវិស័យអប់រំ។ កម្មវិធីសិក្សានេះនឹងត្រូវប្រើដើម្បីបណ្តុះបណ្តាលគរុនិស្សិត ទាំងអស់របស់វិទ្យាស្ថានជាតិអប់រំ។ ហើយកម្មវិធីសិក្សានេះផ្តោត ទៅលើកម្មវិធីកុំព្យូទ័រភាសាខ្មែរ, ការគ្រប់គ្រងហ្វូហ្គលដ្រាយ, ថ្នាក់រៀននិម្មិតហ្គូហ្គល, បណ្តាញសង្គម( តេលេក្រាម, ទំព័រហ្វេសប៊ុក, ក្រុមហ្វេសប៊ុក ), ការបង្រៀនថ្នាក់ទាំងមូលដែលមានលក្ខណៈអន្តរកម្ម ។

ម្យ៉ាងវិញទៀត គរុនិស្សិតនឹងទទួលបានចំណេះដឹង និងបទពិសោធន៍ជាច្រើនក្នុងការប្រើប្រាស់ បច្ចេកវិទ្យាសម្រាប់ការបង្រៀននិងការរៀនពីចម្ងាយ ដើម្បីធ្វើឱ្យការបង្រៀននិងការរៀនសូត្រមានលក្ខណៈអន្តរកម្មថែមទៀត។

## ២- គោលបំណង

គរុនិស្សិត នឹងទទួលបានចំណេះដឹងលើកម្មវិធី Open Office, Google drive Management, Google Classroom, Google Meet, Google Hangout, Social Network (Telegram, Facebook page, Facebook group), ការបង្រៀនថ្នាក់ទាំងមូលដែលមានលក្ខណៈអន្តរកម្ម ដោយការប្រើប្រាស់ YouTube Chanel and Zoom application សម្រាប់ឆ្លុះបញ្ចាំងពីការអប់រំថ្មីៗ ។

### ក- វិជ្ជាសម្បទា:

ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាលនេះ គរុនិស្សិតនឹងទទួលបានចំណេះដឹង៖

- រៀបរាប់សៀវភៅសិក្សានិងការងាររដ្ឋបាលបាន
- ប្រាប់ពីការគ្រប់គ្រងឯកសារនៅលើ Google drive
- បង្ហាញការសិក្សាតាមអ៊ីនធឺណិតដោយប្រើកម្មវិធីគាំទ្រនិងប្រព័ន្ធផ្សព្វផ្សាយសង្គម
- បង្ហាញពីរបៀបគ្រប់គ្រងការបង្រៀននិងរៀនតាមអ៊ីនធឺណេត។

### ខ- បំណិនសម្បទា:

- វិភាគការរចនារៀបចំសៀវភៅសិក្សានិងការងាររដ្ឋបាលបានល្អ
- ពន្យល់ពីការគ្រប់គ្រងឯកសារនៅលើ Google drive
- បកស្រាយការរៀបចំ និងបង្កើតសម្ភារៈតាមអ៊ិនធឺណែតបានល្អ
- វិភាគប្រព័ន្ធផ្សព្វផ្សាយសង្គម / បណ្តាញសម្រាប់បង្រៀននិងរៀនបានល្អ។

### គ- ឥរិយាសម្បទា:

- ចូលរួមប្រាស្រ័យទាក់ទងល្អ និងចែករំលែកចំណេះដឹងថ្មីៗក្នុងការបង្រៀននិងរៀនតាមអ៊ីនធឺណេត និងការបង្រៀនផ្ទាល់ជាលក្ខណៈនៃការអប់រំសតវត្សរ៍ទី ២១

### ៣- គោលគំនិតសំខាន់ៗ

- ការយល់ដឹងអំពីការប្រើប្រាស់កម្មវិធីការិយាល័យខ្មែរ
- គ្រប់គ្រងឯកសារលើថាសហ្វូហ្គល
- ការប្រើប្រាស់បណ្តាញសង្គម
- បង្កើតការរៀនតាមអ៊ិនធឺណេត
- បង្កើតការបង្រៀននិងរៀនតាមអ៊ិនធឺណេតតាមរយៈ ការសរសេរស្ក្រីប ការគណនា ការថតវីដេអូលើអេក្រង់ ថតសំឡេង ជីវចល និងការអានលេខកូដ សន្និសីទ (Script writing, Calculation, Screen recording, Video, Capture sound, Animation and code read, Conference) ។

### ៤- រយៈពេល

| មុខវិជ្ជា | រយៈពេល |
|---|---|
| បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន | **៣ ក្រេឌីត ស្មើ ៤៥ ម៉ោងសិក្សា** |

### ៥- ការណែនាំអនុវត្ត

ដើម្បីអនុវត្តការបង្រៀនលើមុខវិជ្ជានេះឱ្យបានជោគជ័យគ្រូបង្រៀនគប្បីត្រូវ៖

- ឱ្យអ្នកសិក្សាក្តាប់បានពីចំណុចគន្លឹះសំខាន់ៗ នៃមេរៀនតាមរយៈការប្រើគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការរៀននិងបង្រៀនជំរុញការសិក្សាតាមបែបសកម្មតាមរយៈការងារជាបុគ្គល ជាដៃគូជាក្រុមនិងការស្រាវជ្រាវឯកសារជំនួយផ្សេងៗ
- សម្របសម្រួលសិស្សក្នុងការក្តាប់បាននូវខ្លឹមសារមេរៀនដោយធ្វើការវិភាគស្ថានភាពនិងការពិភាក្សារកដំណោះស្រាយដើម្បីទទួលបានទាំងចំណេះជំនាញនិងឥរិយាបទដែលសង្គមត្រូវការ។

### ៦- ការវាយតម្លៃ

ការវាយតម្លៃគឺជាចំណុចសំខាន់ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាទទួលបានធៀបទៅនឹងវត្ថុបំណងនៃមេរៀនឬចំណុចអប្បបរមានៃចំណេះអ្នកសិក្សា ដែលគួរទទួលបានបន្ទាប់ពីបានបញ្ចប់ចំណុចនៃការសិក្សានីមួយៗនិងបញ្ចប់មុខវិជ្ជា។ ការវាយតម្លៃរួមមាន៖

- សំណួរផ្ទាល់មាត់
- កិច្ចការផ្ទះ
- កិច្ចការក្រុម
- ការឡើងធ្វើបទបង្ហាញ
- ការអនុវត្តផ្ទាល់ជាមួយកុំព្យូទ័រ
- ការសួរសំណួរ ការពិភាក្សា ការប្រឡង និងការធ្វើគម្រោងស្រាវជ្រាវជាដើម។

### ៧- តារាងកម្មវិធីសិក្សាលម្អិត

| ខ្លឹមសារជំពូកនិងមេរៀន | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១៖ កម្មវិធីការិយាល័យខ្មែរ** | | |

| ខ្លឹមសារជំពូកនិងមេរៀន | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **មេរៀនទី១៖ កម្មវិធីស្លឹករិត**<br>**(Openoffice.org Writer)** | **វិជ្ជាសម្បទា៖**<br>- ប្រាប់អំពីយូនីកូដ និងយូនីកូដខ្មែរ<br>- បង្ហាញអំពីបង្អួចកម្មវិធីស្លឹករឹត<br>- រៀបរាប់ពីការរៀបចំសៀវភៅសិក្សា ( ទំហំក្រដាស រឹម ពុម្ពអក្សរ តារាង រូបភាព ប្រអប់អត្ថបទ រូបរាង )<br>- ប្រាប់ពីមុខងារនៃឧបករណ៍យោង (តារាងមាតិកា បញ្ចូលលេខយោង បញ្ចូលការដកស្រង់ បញ្ចូលចំណងជើង ការបញ្ចូលសញ្ញា សម្គាល់ការដកស្រង់)<br>- ព៌ណនាពីការបោះពុម្ព (វិញ្ញាបនប័ត្រ បញ្ចូលសំបុត្ររួម(mailing merge) បង្កើតស្រោមសំបុត្រ ស្លាក)។<br>**បំណិនសម្បទា ៖**<br>- បកស្រាយពីមូលហេតុដែលយើងសិក្សាពីយូនីកូដខ្មែរ<br>- ពន្យល់ពីបង្អួចកម្មវិធីស្លឹករឹត<br>- បកស្រាយពីការរៀបចំសៀវភៅសិក្សា<br>- វិភាគពីគុណប្រយោជន៍របស់មុខងារនៃឧបករណ៍យោងផ្សេងៗ<br>- ពន្យល់ពីការបោះពុម្ពឯកសារ។<br>**ចរិយាសម្បទា ៖**<br>- ចូលរួមប្រើប្រាស់និងវាយអក្សរខ្មែរបានលឿនបំផុតតាមក្បួន យូនីកូដខ្មែរ<br>- មានចិត្តស្រលាញ់ការប្រើប្រាស់កម្មវិធីស្លឹករិត ។ | **៣ម៉** |
| **មេរៀនទី២៖ កម្មវិធីនព្វន្ត**<br>**(Openoffice.org Calc)** | **វិជ្ជាសម្បទា៖**<br>- រៀបរាប់អំពីកម្មវិធីនព្វន្ត និងអាចធ្វើការងារនៅលើក្រឡា និងសន្លឹក<br>- បង្ហាញពីរបៀបគណនាប្រមាណវិធីផ្សេងៗ<br>- ពណ៌នាពីការតម្រងនិងតម្រៀនទិន្នន័យ។<br>**បំណិនសម្បទា៖**<br>- បកស្រាយពីសារប្រយោជន៍នៃការប្រើប្រាស់កម្មវិធីនព្វន្ត<br>- វិភាគពីការធ្វើការងារនៅលើក្រឡា និងសន្លឹក<br>- ពន្យល់ពីរបៀបគណនាប្រមាណវិធីផ្សេងៗ<br>- ពន្យល់ពីការប្រើប្រាស់តម្រងនិងតម្រៀបទិន្នន័យ។<br>**ចរិយាសម្បទា៖** | **៣ម៉** |

| ខ្លឹមសារជំពូកនិងមេរៀន | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| | - ចូលចិត្តប្រើប្រាស់កម្មវិធី នព្វន្ត<br>- ចូលរួមក្នុងប្រើប្រាស់កម្មវិធី នព្វន្ត។ | |
| **មេរៀនទី៣៖ កម្មវិធីពិព័រណ៌**<br>**(Openoffice.org Impress )** | **វិជ្ជាសម្បទា ៖**<br>- បង្ហាញដឹងពីការសិក្សាកម្មវិធីពិព័រណ៌<br>- ប្រាប់អំពីបង្អួចនៃកម្មវិធីពិព័រណ៌<br>- រៀបរាប់ពីរបៀបការជ្រើសប្លង់ស្លាយ<br>- ពណ៌នាពីរបៀបរចនា វិដេអូ និងធ្វើទ្រង់ទ្រាយអត្ថបទនៅក្នុងស្លាយ<br>- ប្រាប់ពីរបៀបបញ្ចូលរូបរាងស្វ័យប្រវត្តិ<br>- បង្ហាញពីរបៀបនៃការកំណត់តំណខ្ពស់ស្លាយ<br>- ប្រាប់ពីរបៀបនៃការបោះពុម្ពស្លាយ។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីការប្រើប្រាស់កម្មវិធីពិព័រណ៌<br>- វិភាគពីការប្រើប្រាស់និងការជ្រើសប្លង់ស្លាយ<br>- បកស្រាយពីរបៀបរចនា វីដេអូ និងធ្វើទ្រង់ទ្រាយអត្ថបទនៅក្នុងស្លាយ<br>- បកស្រាយពីរបៀបបញ្ចូលរូបរាងស្វ័យប្រវត្តិ<br>- ពន្យល់ពីការកំណត់តំណខ្ពស់<br>- ពន្យល់ពីការបោះពុម្ពស្លាយ។<br>**ចរិយាសម្បទា ៖**<br>- ចូលចិត្តប្រើប្រាស់កម្មវិធីពិព័រណ៌<br>- ចូលរួមក្នុងការប្រើប្រាស់កម្មវិធី ពិព័រណ៌។ | **៣ម៉** |
| **ជំពូកទី ២៖ Google Space សម្រាប់ការអប់រំ (Google Space for Education)** | | |
| **មេរៀនទី១៖ ការគ្រប់គ្រងថាសឃ្លាំងផ្ទុក (Google drive management)** | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់ពីការចុះឈ្មោះគណនី Gmail<br>- បង្ហាញពីការចូលគណនី Gmail<br>- ប្រាប់ពីរបៀប បង្កើតថត គ្រប់គ្រងឯកសារនិងថតឯកសារ។<br>- បង្ហាញពីការចែករំលែកថាស (Drive sharing)។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ការចុះឈ្មោះនិងចូលគណនី Gmail<br>- ពន្យល់ពីការបង្កើតថត គ្រប់គ្រងឯកសារនិងថត | **៣ម៉** |

| ខ្លឹមសារជំពូកនិងមេរៀន | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| | ឯកសារ។<br>- ពន្យល់ពីការចែករំលែកថាស (Drive sharing)។<br>**ចរិយាសម្បទា ៖**<br>- មានស្មារតីប្រើប្រាស់ឯកសារជាប្រព័ន្ធអេឡិចត្រូនិក។ | |
| **មេរៀនទី២៖ Google docs** | **វិជ្ជាសម្បទា ៖**<br>- បង្ហាញពីការចូលទៅកាន់ Google Docs<br>- រៀបរាប់ពីការប្រើប្រាស់ ចែករំលែក និងគ្រប់គ្រងសិទ្ធនៅលើ Google Docs។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីការចូលទៅកាន់ Google Docs<br>- បកស្រាយពីការប្រើប្រាស់ ចែករំលែក និងគ្រប់គ្រងសិទ្ធនៅលើ Google Docs។<br>**ចរិយាសម្បទា ៖**<br>- មានស្មារតី ប្រើប្រាស់ Google docs នៅបណ្តាញ។ | **៣ម៉**" |
| **មេរៀនទី៣៖ Google spreadsheets** | **វិជ្ជាសម្បទា ៖**<br>- បង្ហាញពីការចូលទៅកាន់ Google spreadsheets<br>- រៀបរាប់ពីការប្រើប្រាស់ ចែករំលែក និងគ្រប់គ្រងសិទ្ធនៅលើ Google spreadsheets។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីការចូលទៅកាន់ Google spreadsheets<br>- បកស្រាយពីការប្រើប្រាស់ ចែករំលែក និងគ្រប់គ្រងសិទ្ធនៅលើ Google spreadsheets។<br>**ចរិយាសម្បទា ៖**<br>- មានស្មារតីក្នុងការប្រើប្រាស់ Google spreadsheets នៅបណ្តាញ។ | **៣ម៉**" |
| **មេរៀនទី៣៖ Google Slides** | **វិជ្ជាសម្បទា ៖**<br>- បង្ហាញពីការចូលទៅកាន់ Google Slides<br>- រៀបរាប់ពីការប្រើប្រាស់ ចែករំលែក និងគ្រប់គ្រងសិទ្ធនៅ លើ Google Slides។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីការចូលទៅកាន់ Google Slides<br>- បកស្រាយពីការប្រើប្រាស់ ចែករំលែក និងគ្រប់គ្រង | **៣ម៉**" |

| ខ្លឹមសារជំពូកនិងមេរៀន | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| | សិទ្ធនៅលើ Google Slides។<br>**ចរិយាសម្បទា ៖**<br>- មានស្មារតីប្រើប្រាស់ Google Slides នៅបណ្តាញ។ | |
| **មេរៀនទី៤៖ Google forms** | **វិជ្ជាសម្បទា ៖**<br>- បង្ហាញពីការចូលទៅកាន់ Google forms<br>- ប្រាប់ពីការបង្កើតសំណួរនិងគ្រប់គ្រងចម្លើយ<br>- រៀបរាប់ពីការគ្រប់គ្រងរចនាសម្ព័ន្ធនៅក្នុងGoogle forms<br>- បង្ហាញពីការកំណត់សិទ្ធនិងចែករំលែកសំណួរនិងចម្លើយ។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីការចូលទៅកាន់ Google forms<br>- វិភាគពីការបង្កើតសំណួរនិងគ្រប់គ្រងចម្លើយ<br>- ពន្យល់ពីការគ្រប់គ្រងរចនាសម្ព័ន្ធនៅក្នុងGoogle forms<br>- បកស្រាយពីការកំណត់សិទ្ធនិងចែករំលែកសំណួរនិងចម្លើយ។<br>**ចរិយាសម្បទា ៖**<br>- ស្រលាញ់ និងចូលចិត្ត ប្រើប្រាស់ Google forms ក្នុងការបង្កើតសំណួរ/ចម្លើយ និងការងារផ្សេងៗនៅលើបណ្តាញ។ | **៣ម៉** |
| **មេរៀនទី៤៖ Google Classroom** | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់ពីសារប្រយោជន៍នៃការប្រើប្រាស់ Google Classroom<br>- បង្ហាញពីការចូលទៅកាន់ Google Classroom<br>- បង្ហាញពីរបៀបនៃបង្កើតថ្នាក់សម្រាប់គ្រូនិងសិស្ស<br>- ប្រាប់ពីរបៀបកំណត់សិទ្ធិក្នុងការប្រើប្រាស់<br>- រៀបរាប់ពីរបៀបបង្កើតមេរៀន សំណួរ និងកិច្ចការផ្សេងៗ និងក្នុង Google Classroom<br>- បង្ហាញពីរបៀបនៃការកែសំណួរនិងការដាក់ពិន្ទុសិស្ស។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីប្រយោជន៍នៃការប្រើប្រាស់ Google Classroom<br>- ពន្យល់ពីរបៀបនៃការចូលទៅកាន់ Google Classroom | **៣ម៉** |

| ខ្លឹមសារជំពូកនិងមេរៀន | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| | - ពន្យល់ពីការបង្កើតថ្នាក់សម្រាប់គ្រូនិងសិស្ស<br>- ពន្យល់ពីការកំណត់សិទ្ធិក្នុងការប្រើប្រាស់<br>- វិភាគពីរបៀបបង្កើតមេរៀន សំណួរ និងកិច្ចការ<br>- ផ្សេងៗ និងក្នុង Google Classroom<br>- វិភាគពីរបៀបនៃការកែសំណួរនិងការដាក់ពិន្ទុសិស្ស។<br>**ចរិយាសម្បទា ៖**<br>- ស្រលាញ់និងចូលចិត្ត ប្រើប្រាស់ Google Classroom សម្រាប់ការបង្រៀន ការរៀន ការបង្កើតមេរៀន សំណួរ ចម្លើយ និងការងារផ្សេងៗនៅលើបណ្ដាញ។ | |
| **ជំពូកទី៣៖ ប្រព័ន្ធផ្សព្វផ្សាយសង្គម (Social media)** | | |
| **មេរៀនទី១៖ កម្មវិធីតេលេក្រាម**<br>**(Telegram Application)** | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់ពីសារប្រយោជន៍នៃកម្មវិធី តេលេក្រាម<br>- បង្ហាញពីការដំឡើងនិងការចូលកម្មវិធី តេលេក្រាម<br>- ប្រាប់ពីរបៀបបង្កើតនិងគ្រប់គ្រងក្រុម<br>- ប្រាប់ពីរបៀបបន្ថែមនិងលប់សមាជិក<br>- រៀបរាប់ពីការគ្រប់គ្រងឈែនណែល<br>- បង្ហាញពីការទាញយកនិងលុបឯកសារផ្សេងៗ។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីសារប្រយោជន៍នៃកម្មវិធី តេលេក្រាម<br>- បកស្រាយពីការដំឡើងនិងការចូលកម្មវិធី តេកេក្រាម<br>- ពន្យល់ពីរបៀបបង្កើតនិងគ្រប់គ្រងក្រុម<br>- បកស្រាយពីរបៀបបន្ថែមនិងលប់សមាជិក<br>- វិភាគពីការគ្រប់គ្រងឈែនណែល<br>- ពន្យល់ពីការទាញយកនិងលុបឯកសារផ្សេងៗ។<br>**ចរិយាសម្បទា ៖**<br>- ស្រលាញ់និងចូលចិត្ត ប្រើប្រាស់កម្មវិធីតេលេក្រាម សម្រាប់ទំនាក់ទំនង ការបង្រៀន ការរៀន ការផ្ដល់ សំណួរ ចម្លើយមេរៀន និងការងារផ្សេងៗនៅលើ បណ្ដាញ។ | **៣ម៉** |
| **មេរៀនទី២៖ ហ្វេសប៊ុក**<br>**(Facebook)** | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់សារប្រយោជន៍កម្មវិធី ហ្វេសប៊ុក<br>- ប្រាប់ពីរបៀបការដំឡើង ការចុះឈ្មោះនិងចូលកម្មវិធី<br>- បង្ហាញពីការបង្កើតក្រុមនិងបន្ថែមសមាជិក | **៣ម៉** |

| ខ្លឹមសារជំពូកនិងមេរៀន | លទ្ធផលរំពឹងទុក | ម៉ោង |
| --- | --- | --- |
| | - រៀបរាប់ពីការគ្រប់គ្រងនិងលុបក្រុម<br>- ប្រាប់ពីរបៀបការគ្រប់គ្រង Page<br>- បង្ហាញពីការគ្រប់គ្រង ឯកសារផ្សេងៗ។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីសារប្រយោជន៍កម្មវិធី ហ្វេសប៊ុក<br>- វិភាគពីរបៀបចុះឈ្មោះ ការចូលកម្មវិធី បង្កើតក្រុមនិងបន្ថែមសមាជិក<br>- ពន្យល់ពីការគ្រប់គ្រងក្រុម លុប និងប្រាប់ពីរបៀបប្រើប្រាស់ Page<br>- វិភាគពីការគ្រប់គ្រងឯកសារផ្សេងៗ។<br>**ចរិយាសម្បទា ៖**<br>- ស្រលាញ់និងចូលចិត្តប្រើប្រាស់កម្មវិធីហ្វេសប៊ុកសម្រាប់ទំនាក់ទំនង ការបង្រៀន ការរៀន ការផ្តល់សំណួរ ចម្លើយមេរៀននិងការងារផ្សេងៗនៅលើបណ្តាញ។ | |
| **ជំពូកទី៤៖ ការបង្រៀន និង រៀនតាមបែបអន្តរកម្ម (Interactive teaching and learning)** | | |
| **មេរៀនទី១៖ កម្មវិធីហ្ស៊ូម**<br>**(Zoom application)** | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់សារប្រយោជន៍កម្មវិធីហ្ស៊ូម<br>- ប្រាប់ពីរបៀបនៃការដំឡើង ការចុះឈ្មោះ និង ចូលកម្មវិធី។<br>- បង្ហាញពីការបង្កើតទំព័រដើម (new meeting, joining a meeting, scheduling a meeting, sharing screen)<br>- ប្រាប់ពីរបៀបនៃការប្រើប្រាស់មុខងារជជែក<br>- រៀបរាប់ពីរបៀបប្រើប្រាស់មុខងារក្នុងការប្រជុំ<br>- បង្ហាញពីការគ្រប់គ្រងឯកសារផ្សេងៗ។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីសារប្រយោជន៍កម្មវិធីហ្ស៊ូម<br>- បកស្រាយពីរបៀបដំឡើង ចុះឈ្មោះ និងចូលកម្មវិធី<br>- ពន្យល់ពីការបង្កើតទំព័រដើម<br>- វិភាគពីការប្រើប្រាស់មុខងារជជែក<br>- ពន្យល់ពីរបៀបប្រើប្រាស់មុខងារសម្រាប់ប្រជុំ<br>- បង្ហាញពីការគ្រប់គ្រងឯកសារផ្សេងៗ។ | **៣ម៉** |

| ខ្លឹមសារជំពូកនិងមេរៀន | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| | **ចរិយាសម្បទា ៖**<br>- ចូលរួមប្រើប្រាស់កម្មវិធី ហ្ស៊ូម សម្រាប់ទំនាក់ទំនង ការបង្រៀន ការរៀន ការផ្តល់សំណួរចម្លើយមេរៀន និងការងារផ្សេងៗនៅលើបណ្តាញ។ | |
| **មេរៀនទី២៖ Google Meet** | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់ពីសារប្រយោជន៍នៃកម្មវិធី Google Meet<br>- ប្រាប់ពីរបៀបដំឡើង ការចុះឈ្មោះ និងចូលកម្មវិធី<br>- បង្ហាញពីការបង្កើតទំព័រដើម (new meeting, joining a meeting, scheduling a meeting, sharing screen)<br>- ប្រាប់ពីរបៀបប្រើប្រាស់មុខងារជជែក<br>- រៀបរាប់ពីរបៀបប្រើប្រាស់មុខងារសម្រាប់ប្រជុំ។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីសារប្រយោជន៍កម្មវិធី Google Meet<br>- វិភាគពីរបៀបដំឡើង ចុះឈ្មោះ និងចូលកម្មវិធី<br>- ពន្យល់ពីការបង្កើតទំព័រដើម<br>- បកស្រាយពីការប្រើប្រាស់មុខងារជជែក<br>- ពន្យល់ពីរបៀបនៃការប្រើប្រាស់មុខងារសម្រាប់ប្រជុំ។<br>**ចរិយាសម្បទា ៖**<br>- ចូលរួមប្រើប្រាស់កម្មវិធី Google Meet សម្រាប់ទំនាក់ទំនង ការបង្រៀន ការរៀន និងការងារផ្សេងៗ នៅលើបណ្តាញ។ | **៣ម៉** |
| **មេរៀនទី៣៖ កម្មវិធី Kahoot** | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់ពីសារប្រយោជន៍កម្មវិធី Kahoot<br>- បង្ហាញពីការបង្កើតនិងចូលគណនី Kahoot<br>- ប្រាប់ពីរបៀបប្រើប្រាស់ Kahoot<br>- រៀបរាប់ពីការបង្កើតសំណួរសម្រាប់សិស្សឆ្លើយ។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីសារប្រយោជន៍កម្មវិធី Kahoot<br>- ពន្យល់ពីការបង្កើតនិងចូលគណនី Kahoot<br>- បកស្រាយពីរបៀបប្រើប្រាស់ Kahoot<br>- វិភាគពីរបៀបបង្កើតសំណួរសម្រាប់សិស្សឆ្លើយ។<br>**ចរិយាសម្បទា ៖**<br>- ចូលរួមប្រើប្រាស់កម្មវិធី Kahoot សម្រាប់បង្កើត | **៣ម៉** |

| ខ្លឹមសារជំពូកនិងមេរៀន | លទ្ធផលរំពឹងទុក | ម៉ោង |
| --- | --- | --- |
| | សំណួរសាកល្បងសមត្ថភាពសិស្សក្រោយបញ្ចប់មេរៀនដែលត្រូវធ្វើនៅលើបណ្ដាញ។ | |
| **មេរៀនទី៤៖ កម្មវិធីថតមេរៀន** | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់ពីសារប្រយោជន៍កម្មវិធីថតមេរៀន<br>- បង្ហាញពីការដំឡើងនិងប្រើកម្មវិធីថតមេរៀន<br>- ប្រាប់ពីរបៀបថតវីដេអូ (Video Capture)<br>- បង្ហាញពីរបៀបថតអេក្រង់ (Screen Recorder)<br>- ប្រាប់ពីការរក្សាទុកនិងលុបឯកសារ។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីសារប្រយោជន៍កម្មវិធីថតមេរៀន<br>- បកស្រាយពីការដំឡើងនិងប្រើកម្មវិធីថតមេរៀន<br>- ពន្យល់ពីរបៀបថតវីដេអូ (Video Capture)<br>- បកស្រាយពីរបៀបថតអេក្រង់ (Screen Recorder)<br>- ពន្យល់ពីការរក្សាទុកនិងលុបឯកសារ។<br>**ចរិយាសម្បទា ៖**<br>- ស្រលាញ់និងចូលចិត្តប្រើប្រាស់កម្មវិធីថតមេរៀនក្នុងការថតមេរៀននិងការងារផ្សេងៗសម្រាប់ផ្ដល់ឲ្យសិស្សយកទៅសិក្សា។ | **៣ម៉** |
| **មេរៀនទី៥៖ កម្មវិធីចាក់វីដេអូ** | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់ពីសារប្រយោជន៍កម្មវិធីចាក់វីដេអូ<br>- បង្ហាញពីការដំឡើងនិងប្រើកម្មវិធីចាក់វីដេអូ<br>- ប្រាប់ពីការគ្រប់គ្រងនិងផ្លាស់ប្ដូរកម្មចាក់វីដេអូទៅតាមតម្រូវការ។<br>**បំណិនសម្បទា ៖**<br>- ពន្យល់ពីសារប្រយោជន៍កម្មវិធីចាក់វីដេអូ<br>- វិភាគពីការដំឡើងនិងប្រើកម្មវិធីចាក់វីដេអូ<br>- ពន្យល់ពីគ្រប់គ្រងនិងផ្លាស់ប្ដូរកម្មវិធីចាក់វីដេអូទៅតាមតម្រូវការ។<br>**ចរិយាសម្បទា ៖**<br>- ស្រលាញ់និងចូលចិត្តប្រើប្រាស់កម្មវិធីចាក់វីដេអូក្នុងការមើលមេរៀន និងការងារផ្សេងៗសម្រាប់ផ្ដល់ឲ្យសិស្សយកទៅសិក្សា។ | **៣ម៉** |

## ៨- ឯកសារយោង

### ក- ភាសាខ្មែរ

- ក្រសួងអប់រំ យុវជន និងកីឡា *កម្មវិធីកុំព្យូទ័រភាសារខ្មែរ* (២០០៨)

### ខ- ភាសាអង់គ្លេស

- HOFFMAN, C. (2017, July 3). howtogeek. Retrieved June 12, 2019, from howtogeek: https://www.howtogeek.com/128028/htg-explains-whats-the-difference-between-cc-and-bcc-when-sending-an-email/
- Sne, S. (Writer). (2014). [Motion Picture]. Retrieved June 12, 2019, from https://www.youtube.com/watch?v=nSg9zflwZpo
- Spencer, L. (2017, May 2017). business. Retrieved June 10, 2019, from business: https://business.tutsplus.com/articles/learn-how-to-use-gmail--cms-28860
- Tschabischer, H. (2019, February 18). lifewire. Retrieved June 12, 2019, from lifewire: https://www.androidauthority.com/

### គ- គេហទំព័រ

- https://www.androidauthority.com/
- https://www.benlcollins.com/
- https://www.brightcarbon.com/
- https://support.google.com/
- https://www.slideshare.net/
- https://support.zoom.us/hc/en-us/categories/201137166
- http://cambodia4point0.org/zoomapplication#.XqZR0mgzbIU
- https://www.camcert.gov.kh/zoom-online-meeting-security-tips/
  A Review of Facebook Research in the Social Sciences, 2012
- https://www.facebook.com/facebookmedia/solutions/news-feed
- https://www.facebook.com/help/110920455663362
- https://www.wikihow.com/Use-Facebook-Messenger
- https://web.facebook.com/help/messenger-app/?_rdc=1&_rdr
- https://medium.com/@kiesp/tutorials-how-to-integrate-dialogflow-with-facebook-messenger-f8b9e9fa6a3e
- https://web.facebook.com/business/ Page s?_rdc=1&_rdr

# វិធាយតម្លៃលទ្ធផលសិក្សា

## ១- សេចក្តីផ្តើម

មុខវិជ្ជានេះត្រូវបានរៀបចំឡើងដើម្បីសិក្សាពីទំនាក់ទំនងរវាងកំណែទម្រង់ និងការវាយតម្លៃលទ្ធផលសិក្សា បញ្ញត្តិទូទៅជាមូលដ្ឋាននៃការវាយតម្លៃ ការបង្កើតវិញ្ញាសាតេស្តសម្រាប់វាយតម្លៃការសិក្សារបស់សិស្ស ភាពខុសគ្នានៃការវាយតម្លៃការអប់រំនិងការវាយតម្លៃក្នុងថ្នាក់ ព្រមទាំងរបៀបនៃការបង្កើតតេស្ត។ ទំនាក់ទំនងរវាងសំណួរតេស្ត ការវិភាគធាតុនៃសំណួរតេស្ត ការបង្រៀនដែលផ្អែកលើសមត្ថភាពនិងការធ្វើតេស្ត និងរបៀបនៃការបន្ស៊ីគ្នាពីវត្ថុបំណងនៃកម្មវិធីសិក្សាទៅនឹងលទ្ធផលរំពឹងទុកនៃការសិក្សាក៏ត្រូវបានលើកយកមកបង្ហាញ និងអនុវត្តក្នុងអំឡុងពេលវគ្គសិក្សានេះដែរ។ ជាងនេះទៅទៀត ទ្រឹស្តីជាគំរូក្នុងការរៀបចំការវាយតម្លៃ ការវិភាគនិងបកស្រាយលទ្ធផលតេស្ត និងការប្រើប្រាស់បច្ចេកវិទ្យាត្រូវបានបញ្ជ្រាបនៅក្នុងវគ្គសិក្សានេះ ដើម្បីឱ្យគរុនិស្សិតមានទស្សនៈទូលំទូលាយនិងអភិវឌ្ឍចំណេះដឹងលើការវាយតម្លៃការសិក្សារបស់សិស្ស។

## ២- គោលបំណង

មុខវិជ្ជានេះមានគោលបំណងដើម្បីៈ

- បណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តមឱ្យក្លាយជាអ្នកមានជំនាញក្នុងការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយវិជ្ជាជីវៈសមស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន
- លើកកម្ពស់សមត្ថភាពរៀបចំការវាយតម្លៃលទ្ធផលសិក្សា ឱ្យឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីសិក្សានិងលទ្ធផលរំពឹងទុកនៅតាមកម្រិតថ្នាក់។

## ៣- វត្ថុបំណង

### ក- វិជ្ជាសម្បទា

- សិក្សាឈ្វេងយល់ពីបរិបទទូទៅនៃការវាយតម្លៃ និងទិសដៅអនាគតលើការវាយតម្លៃថ្នាក់ជាតិ
- បកស្រាយបានពីការវាយតម្លៃការសិក្សារបស់សិស្សគឺជាផ្នែកមួយនៃកំណែទម្រង់វិស័យអប់រំ
- បកស្រាយបានពីបញ្ញត្តិជាមូលដ្ឋាន ក្របខណ្ឌការវាយតម្លៃ និងដំណើរការការវាយតម្លៃការសិក្សារបស់សិស្ស
- កំណត់បានពីចរិតលក្ខណៈនៃការវាយតម្លៃលទ្ធផលសិក្សានៅសតវត្សទី២១
- សិក្សាឈ្វេងយល់ពីទ្រឹស្តីជាគំរូក្នុងការរៀបចំការវាយតម្លៃលទ្ធផលសិក្សា
- បកស្រាយបានពីបម្រើបម្រាស់វត្ថុបំណងនៃការបង្រៀនក្នុងការវាយតម្លៃការសិក្សារបស់សិស្ស

### ខ- បំណិនសម្បទា

- កំណត់បានពីគោលបំណង និងសារៈសំខាន់ដែលទាក់ទងទៅនៃការវាយតម្លៃលទ្ធផលសិក្សា
- ពិភាក្សាពីដំណើរការ និងគោលការណ៍លើការវាយតម្លៃផ្អែកលើបទដ្ឋានគតិយុត្តិ
- បង្កើតវិញ្ញាសាតេស្ត ឈរលើការវិនិច្ឆ័យដែលមានកម្រិតនៃភាពជឿជាក់ខ្ពស់ និងផលជះក្នុងការវាយតម្លៃក្នុងការបង្រៀននិងរៀន
- វិភាគនិងសំយោគបញ្ហាដែលពាក់ព័ន្ធជាមួយការបង្កើតតេស្ត និងការប្រើប្រាស់សូចនាករក្នុងការកំណត់
- កំណត់ខ្លឹមសារលើការបកស្រាយលទ្ធផល និងការវិភាគពិន្ទុតេស្ត
- បញ្ជ្រាបចំណេះដឹងពីការប្រើប្រាស់បច្ចេកវិទ្យាក្នុងការវាយតម្លៃ។

**គ- ចរិយាសម្បទា**

- យកចិត្តទុកដាក់ក្នុងការចូលរួមអភិវឌ្ឍគោលដៅវាយតម្លៃថ្នាក់ជាតិសម្រាប់អនាគត

- មានស្មារតីយកចិត្តទុកដាក់ក្នុងការចូលរួមអភិវឌ្ឍគោលដៅវាយតម្លៃថ្នាក់ជាតិសម្រាប់អនាគត

- មានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តតេស្តរង្វាយតម្លៃសមស្របទៅនឹងក្របខណ្ឌរង្វាយតម្លៃជាប្រចាំ

- មានទំនួលខុសត្រូវ និងជំនឿជាក់លើប្រព័ន្ធវាយតម្លៃការសិក្សា ដើម្បីអភិវឌ្ឍសមត្ថភាពសិស្សានុសិស្ស និងលើកម្ពស់គុណភាពនៃការងារអប់រំ

- មានឆន្ទៈក្នុងការសិក្សាទ្រឹស្តី បទបញ្ញត្តិ និងគោលការណ៍ថ្មីៗក្នុងក្របខណ្ឌវាយតម្លៃការសិក្សាដែលជាតម្រូវការជាក់ស្តែងសម្រាប់អភិវឌ្ឍសមត្ថភាពអ្នកសិក្សា ដែលជាគម្រូល្អដល់សិស្សនិស្សិតនិងភាគីពាក់ព័ន្ធ។

## ៣- គោលគំនិតសំខាន់ៗ

មុខវិជ្ជាចែកជាបីផ្នែកដែលផ្តោតលើគោលគំនិតសំខាន់ៗក្នុងខ្លឹមសារបង្រៀនចំនួន១១ដូចខាងក្រោម៖

**ជំពូក I៖ មូលដ្ឋានគ្រឹះនៃការវាយតម្លៃការសិក្សារបស់សិស្ស**

មេរៀនទី១៖កំណែទម្រង់ការអប់រំ និងការវាយតម្លៃការសិក្សារបស់សិស្ស

មេរៀនទី២៖ ក្របខណ្ឌវាយតម្លៃការសិក្សារបស់សិស្ស

មេរៀនទី៣៖ មូលដ្ឋានគ្រឹះនៃរង្វាយតម្លៃការរបស់សិស្ស

មេរៀនទី៤៖ ទ្រឹស្តីនៃការវាយតម្លៃអប់រំ

**ជំពូក II៖ ដំណើរការនៃការបង្កើតវិញ្ញាសា**

មេរៀនទី៥៖ វត្ថុបំណងនៃការបង្រៀន

មេរៀនទី៦៖ វិធីសាស្រ្តនៃការវាយតម្លៃការសិក្សា ដោយផ្ទាល់ និងដោយប្រយោល

មេរៀនទី៧៖ ការរៀបចំសំណួរតេស្ត

មេរៀនទី៨៖ ការវិភាគសំណួរតេស្ត

មេរៀនទី៩៖ការបកស្រាយលទ្ធផល និងការវិភាគពិន្ទុតេស្ត

**ជំពូក III៖ បរិបទសកល និងបច្ចេកវិទ្យានៃការវាយតម្លៃ**

មេរៀនទី១០៖ ការប្រឡងតេស្តអន្តរជាតិ និងកញ្ចប់ថវិកា

មេរៀនទី១១៖ បច្ចេកវិទ្យា និងការវាយតម្លៃ

## ៤- របាយម៉ោងសិក្សា

របាយម៉ោងសិក្សា នៃមុខវិជ្ជាក្របខណ្ឌច្បាប់ សម្រាប់ការធានាគុណភាពអប់រំ ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| មុខវិជ្ជា | រយៈពេលសិក្សា |
|---|---|
| ការវាយតម្លៃលទ្ធផលសិក្សា | ៣ ក្រេឌីត ស្មើ ៤៥ ម៉ោងសិក្សា |

## ៥- ការណែនាំអនុវត្ត

ដើម្បីអនុវត្តការបង្រៀនលើមុខវិជ្ជានេះឱ្យបានជោគជ័យគ្រូបង្រៀនគប្បី៖

- ផ្តល់នូវចំណុចគន្លឹះសំខាន់ៗនៃមេរៀន ដើម្បីឱ្យគរុនិស្សិតក្តាប់បានពីគោលបំណង សារៈសំខាន់នៃការវាយតម្លៃការសិក្សា តាមរយៈការសិក្សាបញ្ញត្តិជាមូលដ្ឋាន ក្របខណ្ឌការវាយតម្លៃ និងដំណើរការការវាយតម្លៃ។

- សម្របសម្រួលគរុនិស្សិតក្នុងដំណើរការបង្រៀននិងរៀន ដើម្បីក្តាប់បាននូវខ្លឹមសារមេរៀន ដោយផ្តល់ឱកាសឱ្យពួកគាត់ធ្វើការគិត វិភាគ និងសំយោគលើក្របខណ្ឌនៃការវាយតម្លៃ។

- ផ្តោតលើសកម្មភាពអនុវត្តការវាយតម្លៃការសិក្សារបស់សិស្ស តាមរយៈកិច្ចការស្រាវជ្រាវ ដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍សម្រាប់ពង្រឹងសមត្ថភាពការវាយតម្លៃលទ្ធផលសិក្សា។

## ៦- ការវាយតម្លៃ

ការវាយតម្លៃ គឺជាចំណុចសំខាន់ក្នុងការវាស់ស្ទង់ពីអ្វីដែលគរុនិស្សិតនឹងទទួលបាន ធៀបទៅនឹងវត្ថុបំណងនៃមេរៀន ឬចំណុចអប្បបរមានៃចំណេះដឹងរបស់គរុនិស្សិតដែលគួរទទួលបានបន្ទាប់ពីបានបញ្ចប់ចំណុចនៃការសិក្សានីមួយៗ និងបញ្ចប់មុខវិជ្ជា។ ការវាយតម្លៃទាំងនោះរួមមាន៖

-សំណួរផ្ទាល់មាត់

-កិច្ចការផ្ទះ

-កិច្ចការក្រុម

-ការឡើងធ្វើបទបង្ហាញ

- ការពិភាក្សា ការប្រឡង និងការធ្វើគម្រោងស្រាវជ្រាវជាដើម ។

## ៧- តារាងកម្មវិធីសិក្សាលម្អិត

| | | **ខ្លឹមសារ** | **លទ្ធផលសិក្សារំពឹងទុក** | |
|---|---|---|---|---|
| **ជំពូក I៖ មូលដ្ឋានគ្រឹះនៃវង្វាយតម្លៃការសិក្សារបស់សិស្ស** | | | | ១០.៥ ម៉ |
| | **មេរៀនទី១៖ កំណែទម្រង់ការអប់រំ និងការវាយតម្លៃការសិក្សារបស់សិស្ស** (Educational Reform on Student's Assessment) | | | ១.៥ម៉ |
| | ១.១ | ការវាយតម្លៃលទ្ធផលសិក្សាសិស្សនៅសតវត្សទី២១<br>21st century Assessment | **វិជ្ជាសម្បទា**<br>- កំណត់បានពីចរិតលក្ខណៈនៃការវាយតម្លៃលទ្ធផលសិក្សានៅសតវត្សទី២១តាមរយៈការពិភាក្សាបានត្រឹមត្រូវ<br>- បកស្រាយបានពីរចនាសម្ព័ន្ធនៃការវាយតម្លៃក្នុងសាលារៀនបានត្រឹមត្រូវតាមរយៈការធ្វើបទបង្ហាញ<br>**បំណិនសម្បទា** | |
| | ១.២ | រចនាសម្ព័ន្ធនៃការវាយតម្លៃ<br>Internal school structures for student assessment | | |
| | ១.៣ | ការត្រួតពិនិត្យពីភាគីខាងក្រៅ លើការវាយតម្លៃ<br>supervision for external testing | | |

| | | | | |
|---|---|---|---|---|
| | ១.៤ | ទិសដៅអនាគតលើការវាយតម្លៃថ្នាក់ជាតិ<br>Developing future national assessments | - ប្រើប្រាស់ការត្រួតពិនិត្យពីភាគីពាក់ព័ន្ធខាងក្រៅលើការវាយតម្លៃ ដើម្បីធានាបាននូវគណនេយ្យភាពសាលារៀន<br>**ចរិយាសម្បទា**<br>- មានស្មារតីយកចិត្តទុកដាក់ក្នុងការចូលរួមអភិវឌ្ឍគោលដៅវាយតម្លៃថ្នាក់ជាតិសម្រាប់អនាគត | |
| | **មេរៀនទី២៖ ក្របខណ្ឌវាយតម្លៃការសិក្សារបស់សិស្ស** | | | ៣ម៉ |
| | ២.១ | ដំណើរការនៃការវាយតម្លៃការសិក្សារបស់សិស្សនៅក្នុងបរិបទកម្ពុជា | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីគោលបំណង ដំណើរការ និងប្រព័ន្ធវង្វាយតម្លៃលទ្ធផលសិក្សា ព្រមទាំងអ្នកទទួលខុសត្រូវបានត្រឹមត្រូវតាមរយៈការអានឯកសារដោយខ្លួនឯង និងសង្កេតបទបង្ហាញរបស់គ្រូ<br>- ប្រាប់បានពីកាលកំណត់ និងការអនុវត្ត វង្វាយតម្លៃលទ្ធផលសិក្សាបានត្រឹមត្រូវតាម រយៈការអានឯកសារដោយខ្លួនឯង និងសង្កេតបទបង្ហាញរបស់គ្រូ<br>**បំណិនសម្បទា**<br>- បង្ហាញពីយន្តការនៃការបង្កើតគណៈកម្មការ វង្វាយតម្លៃ និងតួនាទីរបស់ស្ថាប័នពាក់ព័ន្ធបានត្រឹមត្រូវតាមរយៈការអានឯកសារដោយខ្លួនឯង និងសង្កេតបទបង្ហាញរបស់គ្រូ<br>- អនុវត្តតេស្តវង្វាយតម្លៃទាំងបួនកម្រិត ឱ្យឆ្លើយតបនឹងក្របខណ្ឌវង្វាយតម្លៃបានត្រឹមត្រូវតាមរយៈការអនុវត្តនៅក្នុងស្ថាប័ន រៀងៗខ្លួន | |
| | ២.២ | គោលបំណងនៃការវាយតម្លៃលទ្ធផលសិក្សា(ផ្ទៃក្នុង កម្រិតសាលារៀន | | |
| | ២.៣ | ការកំណត់ពេលវេលានិងការអនុវត្តការវាយតម្លៃការសិក្សា | | |
| | ២.៤ | ភាពខុសគ្នារវាងតេស្តស្តង់ដា និងតេស្តរបស់គ្រូ | | |
| | ២.៥ | ការគ្រប់គ្រង និងត្រួតពិនិត្យគុណភាពវង្វាយតម្លៃលទ្ធផលសិក្សា | | |

| | | | | |
|---|---|---|---|---|
| | | | **ចរិយាសម្បទា**<br>- មានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តតេស្តរង្វាយតម្លៃសមស្របទៅនឹងក្របខណ្ឌ រង្វាយតម្លៃជាប្រចាំ។ | |
| | **មេរៀនទី៣៖ មូលដ្ឋានគ្រឹះនៃរង្វាយតម្លៃការរបស់សិស្ស** | | | ៣ម៉ |
| | ៣.១ | និយមន័យ៖ ការវាយតម្លៃ និង ការវាស់វែង | **វិជ្ជាសម្បទា**<br>- ពន្យល់បានពីបញ្ញត្តិសំខាន់ៗនៃការវាយតម្លៃការសិក្សារបស់សិស្សបានត្រឹមត្រូវតាមរយៈការអានឯកសារដោយខ្លួនឯង<br>- រៀបរាប់ពីគោលបំណងនិងសារៈសំខាន់នៃ រង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស<br>**បំណិនសម្បទា**<br>- បកស្រាយពីរបៀបវាយតម្លៃលទ្ធផលសិក្សាក្នុងថ្នាក់រៀន<br>- បង្ហាញភាពខុសគ្នារវាងការវាយតម្លៃតាមដំណាក់កាលនិងការវាយតម្លៃបញ្ចប់តាមរយៈការពិភាក្សាក្រុម<br>**ចរិយាសម្បទា**<br>- មានស្មារតីយកចិត្តទុកដាក់លើកកម្ពស់សមត្ថភាពអនុវត្តលើការវាយតម្លៃការសិក្សារបស់សិស្សបានត្រឹមត្រូវ | |
| | ៣.២ | ការវាយតម្លៃមិនផ្លូវការនិងផ្លូវការ | | |
| | ៣.៣ | ការវាយតម្លៃបែបវិនិច្ឆ័យ | | |
| | ៣.៤ | ការវាយតម្លៃតាមដំណាក់កាលនិងការវាយតម្លៃបញ្ចប់ | | |
| | ៣.៥ | ការវាយតម្លៃការអនុវត្ត និងសមត្ថភាព | | |
| | **មេរៀនទី៤៖ ទ្រឹស្តីនៃការវាយតម្លៃអប់រំ** (Educational Evaluation Theories) | | | ៣ម៉ |
| | ៤.១ | គំរូវាយតម្លៃរបស់លោក Stufflebeam: បរិបទ ធាតុចូល ដំណើរការ និង លទ្ធផល<br>Stufflebeam Model: Context, Input, Process and Product | **វិជ្ជាសម្បទា**<br>- ឈ្វេងយល់ពីទ្រឹស្តីនានា សម្រាប់ជាគំរូក្នុងការវាយតម្លៃការសិក្សារបស់ | |

| | | | | |
|---|---|---|---|---|
| | ៤.២ | គំរូវាយតម្លៃរបស់លោក Kirkpatrick: ប្រតិកម្មតប ការរៀន អាកប្បកិរិយា លទ្ធផល<br>Kirkpatrick Model: Reaction, Learning, Behavior, Result | សិស្សតាមរយៈបទបង្ហាញរបស់គ្រូ និងការអានឯកសារបន្ថែម<br>**បំណិនសម្បទា**<br>- បង្ហាញពីរបៀបនៃការអនុវត្តតាមគំរូវាយតម្លៃ ឆ្លើយតបបរិបទថ្នាក់រៀន និងកញ្ចប់សមត្ថភាពសិស្ស<br>- ជ្រើសរើសទ្រឹស្តីនៃការវាយតម្លៃអប់រំតាមគំរូផ្សេងៗដែលសមស្របតាមគោលបំណងនៃកម្មវិធីអប់រំបានត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់លើការអនុវត្តទ្រឹស្តីនៃការវាយតម្លៃឱ្យមានប្រសិទ្ធភាពខ្ពស់ | |
| **ជំពូក II៖ ដំណើរការនៃការបង្កើតវិញ្ញាសា** | | | | ៣០ម៉ |
| | **មេរៀនទី៥៖ វត្ថុបំណងនៃការបង្រៀន** | | | ៦ម៉ |
| | ៥.១ | សមាសភាគនៃវត្ថុបំណងនៃការបង្រៀន | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីសមាសភាគសំខាន់ៗរបស់វត្ថុបំណងនៃការបង្រៀនតាមរយៈការអានឯកសារ<br>- បង្ហាញពីរបៀបប្រើប្រាស់វត្ថុបំណងនៃការបង្រៀនក្នុងការបង្កើតសំណួរតេស្តតាមរយៈពិភាក្សាក្រុម<br>- ពិពណ៌នាពិគោលការ<br>**បំណិនសម្បទា**<br>- បកស្រាយពីសមាសភាគសំខាន់ៗរបស់វត្ថុបំណងនៃការបង្រៀនតាមរយៈការធ្វើបទបង្ហាញបានត្រឹមត្រូវ<br>- រៀបចំផែនការនៃការធ្វើតេស្តបានសមស្របតាមកម្មវិធីសិក្សានៃមុខវិជ្ជានីមួយៗ | |
| | ៥.២ | ការប្រើប្រាស់វត្ថុបំណងនៃការបង្រៀនក្នុងការបង្កើតសំណួរតេស្ត | | |
| | ៥.៣ | ការរៀបចំផែនការនៃការធ្វើតេស្ត | | |
| | ៥.៤ | គោលការណ៍ណែនាំនៃការបង្កើតតេស្តវាស់វាយតម្លៃលទ្ធផលសិក្សា | | |

| | | | | |
|---|---|---|---|---|
| | | | - វាស់វែងពីការអនុវត្តនៃប្រភេទតេស្ត ទៅតាមកម្រិតនីមួយៗ<br>**ចរិយាសម្បទា**<br>- យកចំណេះដឹងពីការវាយតម្លៃទៅអនុវត្តដែលមានភាពបត់បែន តាមបច្ចេកទេស និងវិធីវាយតម្លៃចម្រុះបានច្បាស់លាស់ | |
| | **មេរៀនទី៦៖វិធីសាស្ត្រនៃការវាយតម្លៃៈ ការធ្វើតេស្តដោយផ្ទាល់ និងដោយប្រយោល** | | | ៦ម៉ |
| | ៦.១ | និយមន័យនៃការធ្វើតេស្ត និង សំណួរតេស្ត | **វិជ្ជាសម្បទា**<br>- បកស្រាយ បានពីបញ្ញត្តិនៃការធ្វើតេស្តដោយផ្ទាល់និងដោយប្រយោល និងសំណួរតេស្តបានត្រឹមត្រូវ<br>- រៀបរាប់បានពីទម្រង់សំណួរផ្សេងៗ ដែលនឹងត្រូវបង្កើតសម្រាប់ការវាយតម្លៃការសិក្សា<br>**បំណិនសម្បទា**<br>- បង្ហាញពីទម្រង់សំណួរតេស្តផ្សេងៗ និងទំនាក់ទំនងរវាងការប្រើប្រាស់ទម្រង់សំណួរ តេស្ត និងឥរិយាបថសិក្សាតាមរយៈការពិភាក្សាក្រុមបានច្បាស់។<br>- បង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិទម្រង់សំណួរតេស្តនីមួយៗ<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ប្រើប្រាស់វិធីសាស្ត្រនៃ ការវាយតម្លៃដោយផ្ទាល់និងប្រយោលបានសមស្របតាមវត្ថុបំណងនៃការវាយតម្លៃ តាមខ្លឹមសារមេរៀន និងឥរិយាបថសិក្សា | |
| | ៦.២ | ទម្រង់សំណួរ-ចម្លើយជ្រើសរើសៈ ពហុជ្រើសរើស ត្រូវ ខុស និងផ្គូផ្គង | | |
| | ៦.៣ | ទម្រង់សំណួរសរសេរចម្លើយខ្លី (បំពេញឃ្លា បំពេញចន្លោះ) | | |
| | ៦.៤ | ទម្រង់សំណួរសរសេរ | | |
| | ៦.៥ | ទម្រង់វាយតម្លៃដោយប្រយោល | | |
| | **មេរៀនទី៧៖ ការរៀបចំសំណួរតេស្ត** | | | ៦ម៉ |

<table>
<tr><td></td><td>៧.១</td><td>ការបំលែងវត្ថុបំណងកម្មវិធីសិក្សាសមត្ថភាពសិក្សាទៅជាសំណួរតេស្ត</td><td rowspan="4">វិជ្ជាសម្បទា<br>- បង្ហាញបានពីទម្រង់នៃបំណែងចែកកម្មវិធីសិក្សាប្រចាំខែ ឆមាសដែលបន្សុីគ្នានឹងកម្មវិធីសិក្សាលម្អិត និងស្តង់ដាកម្មវិធីសិក្សា<br>- ពន្យល់បានពីការបង្កើតគម្រោងលម្អិតសម្រាប់វិញ្ញាសាប្រឡង<br>- បង្ហាញពីរបៀបបង្កើតសំណួរតេស្តតាមរយៈការពិភាក្សានិងបទបង្ហាញបានច្បាស់លាស់<br>បំណិនសម្បទា<br>- កសាងសំណួរតេស្ត និងបង្កើតប័ណ្ណសំណួរ តេស្តបានត្រឹមត្រូវ<br>- បង្កើតអត្រាកំណែនៃសំណួរទម្រង់បើក ដែលអាចឆ្លុះបញ្ចាំងពីកម្រិតសមត្ថភាពរបស់សិស្ស<br>- រៀបចំ និងចងក្រងវិញ្ញាសាប្រចាំខែ និងឆមាសដោយមានចំនួនសំណួរតេស្តតាមសមាមាត្រជាភាគរយ<br>ចរិយាសម្បទា<br>- មានទំនួលខុសត្រូវ និងទំនុកចិត្តក្នុងការរៀបចំសំណួរតេស្តដោយប្រុងប្រយ័ត្ន ដើម្បីធានាបាននូវការអនុវត្តការវាយតម្លៃការសិក្សារបស់មានប្រសិទ្ធភាពនិងគុណភាព</td><td rowspan="4"></td></tr>
<tr><td></td><td>៧.២</td><td>ការបង្កើតគម្រោងលម្អិតតេស្ត</td></tr>
<tr><td></td><td>៧.៣</td><td>ការបង្កើតសំណួរតេស្ត</td></tr>
<tr><td></td><td>៧.៤</td><td>ប័ណ្ណសំណួរតេស្ត Test items card</td></tr>
<tr><td></td><td colspan="3">មេរៀនទី៨៖ ការវិភាគសំណួរតេស្ត</td><td>៦ម៉</td></tr>
<tr><td></td><td>៨.១</td><td>កម្រិតលំបាកនៃសំណួរតេស្ត</td><td>វិជ្ជាសម្បទា</td><td></td></tr>
</table>

| | | | | |
|---|---|---|---|---|
| | ៨.២ | ការប្រើប្រាស់លទ្ធផលតេស្ត | - រៀបរាប់ពីដំណើរការនៃការវិភាគសំណួរតេស្តបានច្បាស់លាស់តាមរយៈបទបង្ហាញរបស់គ្រូ<br>- កំណត់បានពីលក្ខណៈវិនិច្ឆ័យនៃសំណួរ តេស្តតបានច្បាស់លាស់<br>**បំណិនសម្បទា**<br>- គណនាកម្រិតលំបាករបស់សំណួរ និងកម្រិតបែងចែកសមត្ថភាពរបស់សិស្សតាមរយៈសំណួរតេស្តនីមួយៗបានត្រឹមត្រូវ<br>- វិភាគលើកម្រិតលំបាកនៃសំណួរតាមរូបមន្តជាក់លាក់<br>- គណនាភាគរយសិស្សដែលទទួលកម្រិតពិន្ទុនីមួយៗ ដូចដែលបានកំណត់អត្រាកំណែនៃសំណួរទម្រង់សរសេរ ដើម្បីកំណត់ពីលទ្ធផលរំពឹងទុក ឬខ្លឹមសារមេរៀន ដែលត្រូវពង្រឹងនិងកែលម្អការ បង្រៀន។<br>**ចរិយាសម្បទា**<br>- មានទំនួលខុសត្រូវ និងទំនុកចិត្តក្នុងការគណនាកម្រិតលំបាករបស់សំណួរ និងកម្រិតបែងចែកសមត្ថភាពរបស់សិស្សតាមរយៈសំណួរតេស្តនីមួយៗ | |
| | ៨.៣ | ការវិភាគតាម Trace line analysis | | |
| | **មេរៀនទី៩៖ការបកស្រាយលទ្ធផល និងការវិភាគពិន្ទុតេស្ត**<br>Result Finding and interpreting standardized test and scores | | | ៦ម៉ |
| | ៩.១ | **ការសិក្សាស្វែងយល់ពី**លទ្ធផលតេស្ត<br>Understanding Test Results: Test Evaluation and Grading system | **វិជ្ជាសម្បទា**<br>- បកស្រាយបានពីការវាយតម្លៃតេស្ត និងប្រព័ន្ធនៃការដាក់ពិន្ទុ<br>**បំណិនសម្បទា** | |
| | ៩.២ | ការវិភាគ**ពីកម្រិតសុចរិតភាពសូចនាករ**<br>Types of Validity Content, Construct, Criterion related | | |
| | ៩.៣ | ការវិភាគ**ពីកម្រិតនៃភាពជឿជាក់នៃសូចនាករ** | | |

| | | | | |
|---|---|---|---|---|
| | | Reliability: Test-Retest, Alternate form, Interscorer, Internal Consistency | - វិភាគពីកម្រិតនៃសុពលភាពនិងភាពជឿជាក់លើសូចនាករក្នុងការវាយតម្លៃលទ្ធផលសិក្សាបានត្រឹមត្រូវ<br>- បង្ហាញពីរបៀបនៃការបកស្រាយពិន្ទុតេស្តស្តង់ដាបានច្បាស់លាស់<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់អភិវឌ្ឍសូចនាករដើម្បីធានាបាននូវសុពលភាពនិងភាពជឿជាក់ ក្នុងការអនុវត្តការវាយតម្លៃលទ្ធផលសិក្សា | |
| | ៩.៤ | ការបកស្រាយពិន្ទុតេស្តស្តង់ដា<br>Interpreting Standardized Test Scores | | |
| **ជំពូក III៖ បរិបទសកល និងបច្ចេកវិទ្យានៃការវាយតម្លៃ** | | | | ៤.៥ម៉ |
| | **មេរៀនទី១០៖** ការប្រឡងតេស្តអន្តរជាតិ និងកញ្ចប់ថវិកា<br>(International Test Competition and Challenges: Bebras, Mathematical Olympiads) | | **វិជ្ជាសម្បទា**<br>- បង្ហាញសារៈប្រយោជន៍នៃការធ្វើតេស្តអន្តរជាតិ និងការចំណាយ<br>**បំណិនសម្បទា**<br>- រៀបរាប់ពីរបៀបនៃការចូលរួមប្រកួតប្រជែងនិងបញ្ហាប្រឈមមួយចំនួនដែលសិស្សនឹងជួបប្រទះបានច្បាស់លាស់<br>**ចរិយាសម្បទា**<br>- លើកទឹកចិត្តសិស្សឱ្យចូលរួមប្រកួតប្រជែងក្នុងការធ្វើតេស្តអន្តរជាតិជាច្រើន | ១.៥ម៉ |
| | **មេរៀនទី១១៖** បច្ចេកវិទ្យា និងការវាយតម្លៃ<br>Technology and Assessments: Computer Based Testing (CBT) | | | ៣ម៉ |
| | ១១.១ | **និន្នាការបច្ចុប្បន្ន ក្នុងការវាយតម្លៃការសិក្សា**<br>Current Trends in Assessment of Learning | **វិជ្ជាសម្បទា**<br>- បកស្រាយបានពីនិន្នាការនៃការវាយតម្លៃលទ្ធផលសិក្សាក្នុងបរិបទពិភពលោកបានច្បាស់លាស់តាមរយៈនៃការអាននិងបទបង្ហាញរបស់គ្រូ | |
| | ១១.២ | **តួនាទីនៃបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានវិទ្យាក្នុងការវាយតម្លៃការសិក្សា**<br>Role of ICT in Assessment of Learning | | |

| | | | | |
|---|---|---|---|---|
| | ១១.៣ | **ក្របខណ្ឌបច្ចេកវិទ្យាក្នុងការវាយតម្លៃ**<br>Technology-Driven frameworks in assessment | - កំណត់បានពីក្របខណ្ឌបច្ចេកវិទ្យាក្នុងបរិបទនៃការវាយតម្លៃការអប់រំបានច្បាស់លាស់<br>**បំណិនសម្បទា**<br>- ពិភាក្សាពីតួនាទីនៃបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការវាយតម្លៃការសិក្សា ដោយផ្អែកលើបទពិសោធន៍ក្នុងការអនុវត្តបានត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ធ្វើបច្ចុប្បន្នភាពការប្រើប្រាស់បច្ចេកវិទ្យាក្នុងវាយតម្លៃ | |

## ៨- ឯកសារយោង

### ក- ភាសាខ្មែរ


- សម្តេចសង្ឃ ជួន ណាត(១៩៦៧), វចនានុក្រមខ្មែរ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ភ្នំពេញ
- អយក(២០២១), ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+២), ភ្នំពេញ


### ខ- ភាសាអង់គ្លេស


- Eggen Paul D. & Kauchak Don P. (2016). *Educational Psychology, windows On Classrooms;* 10 th Edition. Edinburgh Gate,Harlow,Essex CM20 2JE,England: Pearson Education Limited.
- EQAD. (20018). *K-12 Student Learning Assessment Framework.* Phnom Penh: MoEYS.
- McMillan, J. H. (2018). *Classroom Assessment: Pricipple and Practice that enhace stusent learning and Motivation.* New York: Pearson.
- MoEYS. (2018). *Eduation in Cambodia Finding from Cambocia's Experience In PISA for Development.* Phnom Penh.
- Moreno, R. (2010). Educational psychology. Hoboken, NJ: John Wiley & Sons, Inc.
- Sanstrok, J. W. (2011). Educationa Psychology. 5$^{th}$ edition. New York: Ma Graw Hill.
- Slavin, R. E. (2006). *Educational Psychology Teory and Practice.* New York: Pearson.
- Stufflebeam Daniel L. & Shinkfield Antony J. (2007). *Educational Theory, Models, and Apllication.* Sanfrancissco: Johon Wiley & Sons, Inc.
- Woolfolk, A. (2016). *Educational Psychology*. 13$^{th}$ Edition. Edinburgh Gate, Harlow, Essex CM20 2JE, England: Pearson Education Limited.